ស្នងការRoyចាប់ផ្ដើមបញ្ចេញវោហារៈ

«មានតែLorenzo ខ្លួនឯងដែលត្រូវចូលមកដោះស្រាយរឿងនេះបាន! ជំនួយការគេមិនដឹងថាតើគេនោះ ជួបតាពាងនៅឯណាដោយសារអ្វីហើយ មានរឿងអ្វីដែលធ្វើឱ្យគេជឿស៊ុបលើរឿងមនុស្សស្រី៣៥នាក់កើតឆ្នាំ២០០០នោះដល់ថ្នាក់ហ្នឹងបាន? គ្រប់យ៉ាងមិនសមហេតុផលតែទាំងអស់!»

«ចុះបើជំនួយការនោះខ្លួនឯងនិយាយកុហក?»

លោកឱត សាម៉ុនសួរបកមកវិញ។ រឿងកាន់តែស្មុគស្រម្រាប់ចិត្រា។

ស្នងការRoyលើកក្រដាសសមួយផ្ទាំងចេញមកពីក្នុងសំពាយដែលទុកក្រោមជើង។ គេចាប់ផ្ដើមគូរវាសហើយមាត់វាថា ក្នុងពេលដែលលោកសាម៉ុនបើកឡានបណ្ដើរដៀងភ្នែកមកមើលផង ផ្ទៀងត្រចៀកស្ដាប់ផង។

«យើងគូររឿងទាំងអស់ទុកមើលនៅទីនេះ! រឿងដំបូង អាចថា តាហោឈ្មោះពាង ឬយើងហៅថាករណីថាមពលមេឃដី យកស្រីឆ្នាំរោង៣៥នាក់! ទីពីរ ស្រីៗដែលបាត់បួននាក់ មានទំនាក់ទំនងនឹងកម្មវិធី ចម្លែកពណ៌ព្រះចន្ទ! ទីបី Lorenzoខ្លួនឯងជាអ្នកជួបពួកនាង ហើយពួកនាងបាត់ទៅ! ទីបួន គេ និងមហាវីនមានទំនាស់ រហូតដល់ជួលបរទេសមកបំផ្លាញគ្នាទៅវិញទៅមក!  អ្នកណាម្នាក់មានចេតនាជួយឱ្យLorenzoឈ្នះ ហើយមហាវីនត្រូវគេធ្វើឃាត! ទី៥ ពេលមហាវីនដេក មានគេទៅរៀបចំកម្មវិធីបន្តហើយចាប់ទាំងនុយប៉ូលិស ឯកមាន និងផានូ! ទី៦ គេស្ទាក់ចាប់អ្នកនាង អមរាជា នៅផ្ទះព្រោះនាងមានឆ្នាំរោងចង់បញ្ជាក់ថា ទោះជាមហាវីនមិនឱ្យនាងទៅកម្មវិធីនោះ តែនាងមានឈ្មោះក្នុងបញ្ជី៣៥នាក់សម្រាប់គេ! ទី៧ Roseដឹងរឿងច្រើនក៏ត្រូវគេចាប់ទៅដូចគ្នា! ទី៨គេឱ្យឈុនរាជទៅដោះស្រីៗចេញមក ហើយឱ្យដេវីដចេញមុខទទួលស្គាល់ថាខ្លួនធ្វើការឱ្យLorenzo! ចុងក្រោយគេឱ្យLorenzoរត់! គោលដៅរបស់គេគឺLorenzoសម្រាប់លទ្ធផលទីមួយ ចំណែកលទ្ធផលទីពីរ គឺចង់ទម្លាក់ខ្ញុំចេញពីតំណែង ព្រោះព្រឹកមិញថ្នាក់លើផ្ញើលិខិតមកខ្ញុំថា ខ្ញុំនឹងត្រូវចេញពីតួនាទីក្នុងពេលបីថ្ងៃទៀតបើបិទសំណុំរឿងនេះមិនចេញ! »

គេថាចប់គ្រប់គ្នាស្ងាត់ច្រៀប។

ស្នងការម្នាក់នេះមិនមែនគ្មានបានការដូចដែលលោកឱិត សាម៉ុនតែងតែនិយាយទេ ប៉ុន្តែគេគ្រាន់តែមានចរិតក្រអឺតនិងច្រឡើសបើស ចូលចិត្តយកប្រៀបលើអ្នកណាដែលមានសក្តិតូចជាងខ្លួន។ ទើបនឹងដឹងថាគេត្រូវព្រួនង់ដោយលិខិតផ្លូវការពីថ្នាក់លើបែបនេះសោះ បានជាសំងំស្ងៀមឈឹងក្នុងឡានកាលពីជិះមកដំបូង។

«ឯងគិតយល់អត់ជាតិចិត្រា! បើមិនយល់អត់អីទេ! គ្មានអ្នកណាពិន័យឯងទេ! ខ្ញុំទេដែលត្រូវអស់លក្ខណ៍»

ដល់ពេលនេះហើយ គេអស់សង្ឃឹមយ៉ាងនេះហើយនៅឆ្លៀតងាកមកថាឱ្យនាយសក្តិប្អូនបានទៀត តែចិត្រាហាក់លែងប្រកាន់ខឹង។

«ហេតុអីលោកគិតថាមានគេចង់ធ្វើបាបលោក?»

ឱិត សាម៉ុនសួរមួយៗ។  Royនៅស្ងៀមគាត់សួរបន្ថែម៖

«លោកមានទំនាស់ជាមួយអ្នកណា?»

«ខ្ញុំមួយឆ្នាំៗចាប់ចោរញាត់គុករាប់សិបក្បាល ដល់សួរថាអ្នកណាគុំកួនខ្ញុំខ្លះ ខ្ញុំក៏មិនដឹងនិយាយថាម៉េចដែរ?»

គេហាក់បង្ហាញអាការៈកាន់តែស្មុគ។ មុននេះគេសើច ពេលនេះគេខឹង។ ចិត្រាកាន់តែសំងំមើលស្នងការម្នាក់នេះ។ គេពេលខ្លះមានចរិតដូចតួកំប្លែង ពេលខ្លះ ជាព្រាននារី ហើយពេលខ្លះសុភាពមុខស្រីស្អាត ហើយនៅនឹងមុខខ្លួនវិញគេគឺកំពូលមេនាំរឿងនិងដៀមដាម។

ទោះបីជាយ៉ាងណា ការសន្ទនារបស់ស្នងការនេះជាមួយលោកឧត្តមសេនីយ៍ បង្រៀនគេអំពីអ្វីមួយសន្សឹមៗ។

កំលោះសក្តិប្អូនស្ទើរបទពិសោធន៍  ចាប់អារម្មណ៍ឃើញថាមេប៉ូលិសផ្កាយបីទាំងពីរនាក់ព្យាយាមស្វែងរកចុងកំពូល ឬបាតក្រោមបង្អស់នៃសាច់រឿងដើម្បីកំណត់គោលដៅ។

ឱិត សាម៉ុនជារឿយៗនិយាយថា គោលដៅរបស់ពួកអ្នករៀបចំរឿងនេះ ឡើយគឺធ្វើបាបប៉ូលិសឱ្យបាក់មុខ ចំណែក ស្នងការRoy យល់ថាគេនោះចង់ទម្លាក់តំណែងតួនាទីខ្លួន។

ចុះហេតុអីបានជាគេវាងផ្លូវច្រើនថ្នាក់នេះ?

ហេតុអ្វីមានLorenzo និងមហាវីនក្នុងផែនទីនេះដែរ?

«យើងសង្កត់ករអាប៊ុដេវីដ ដឹងរឿងពិតមិនខាន!»

គេភ្លាត់មាត់និយាយតិចៗទៅតាមចិត្តនឹកឃើញ។ ព្រោះថាក្នុងគំនិតរបស់ចិត្រាពេលនេះ ដេវីដជាបុគ្គលតែម្នាក់នៅក្នុងឫសគល់នៃគំនូសផែនទីដែលRoyទើបនឹងគូ។ គេមកជាកូនចៅមហាវីន គេក៏ទទួលលុយ Lorenzo ហើយជួលប៉ូលិសក្លែងក្លាយចាប់ កូនស្រីឧត្តមសេនីយ៍ ឱត សាម៉ុន ចុងក្រោយឱ្យពួកនោះឆ្លើយដាក់តារាសប្បុរស អ៊ីចឹងមានតែគេនោះជាមេខ្លោង? មិនមែនរាក់កម្រិតនេះទេ? គេប្រាកដជាមានអ្នកនៅពីក្រោយឱ្យគេធ្វើរឿងអស់ទាំងនេះ។

«វាមិននិយាយទេ! វាឆ្លើយថា Lorenzoជាមេវា គឺចប់ហើយ ព្រោះLorenzoនៅមិននៅវត់ធ្វើអី? បើខ្លួនគ្មានទោសហេតុអ្វីរត់? សេណារីយោនេះមើលឱ្យជិតដល់ទៅគឺសាហាវជាមួយតួឯកសប្បុរសនោះជាងគេ ព្រោះថាទោះមួយផែនដីនេះ អ្នកណាក៏ដឹងថាគេទំនងដូចត្រូវអន្ទាក់ តែអន្ទាក់នោះជ្រៅ ប៉ូលិសក៏លាងឱ្យគេមិនរួចដែរ មានតែគេត្រូវចូលមកដោះស្រាយខ្លួនឯង!»

«ខ្ញុំសុំក្រដាសនេះមក!»

ចិត្រានិយាយតិចៗពេលឃើញRoyបត់វាទុក។

សាជាថ្មីRoyសើចក្អាកក្អាយ ហើយនិយាយចំអក៖

«ឃើញអត់! មានរឿងដែលត្រូវរៀនច្រើនទៀត!»

គេថាហើយហុចវាមកឱ្យទាំងកែវភ្នែកដៀមដាម។ រួចរាល់នាយស្នងការងាកមកវិញហើយនិយាយទូរសព្ទទៅកាន់កូនចៅខ្លួន៖

«ខ្ញុំចង់បានរបាយការណ៍លំហូរលុយរបស់គ្រួសារអ្នកទាយម្នាក់ឈ្មោះពាង! ខ្ញុំផ្ញើអាសយដ្ឋានគេទៅឱ្យ និងឈ្មោះ ពេញទាំងប្ដីប្រពន្ធ!»

គេអានមកវិញហើយបើកឯកសារជាច្រើនពិនិត្យមុនពេលនិយាយបញ្ជាបន្ត៖

«ខ្ញុំចង់ជួបគ្រួសាររបស់Lorenzo! ណាត់ឱ្យគេSkype ជាមួយខ្ញុំ កាន់តែឆាប់រឹតតែល្អ»

វគ្គ ផ្ញើបេះដូងនៅជាយព្រៃ

មាន់រងាវធ្វើឱ្យអាណិកជនស្វាងចេញពីដំណេកដែលពេញទៅដោយក្តីស្រមៃរវើរវាយ។ គេខំប្រឹងផ្ទង់សម្លឹងជុំវិញខ្លួន ហើយឈឺក្បាលខ្មោកៗ ពេលខំប្រឹងរកនឹកឡើងមកវិញបណ្តារឿងរ៉ាវអកុសលដែលបានកើតឡើងចំពោះជីវិតខ្លួនកាលពីម្សិល។

ការចងចាំបញ្ចប់បាត់ត្រឹមឡើងជិះម៉ូតូមកជាមួយនាងតូចម្នាក់ដែលគេក៏មិនច្បាស់ថាចំណាំមុខនាង។ នាយធ្មេចភ្នែកសម្រន់អាការៈឈឺក្បាលសន្ធប់។ ទទួលអារម្មណ៍ថាលើថ្ងាសខ្លួននៅមានបិទក្រដាសស្រូបកម្តៅបញ្ជាក់ថា ខ្លួនបានឡើងកម្តៅខ្លាំង ព្រោះតែស្នាមដាច់រលាត់កាលពីល្ងាច។

«ស្រីតូចនោះមែនទេនាំយើងមកកន្លែងនេះ! អ្នកណាបានឃើញយើងខ្លះហើយ?»

ទ្វារឈើចោលសំឡេងងឺត។

គេបើកភ្នែកមកវិញមួយរំពេច ក៏ឃើញនារីមាឌល្អិតម្នាក់ដើរចូលមកបាំងនឹងពន្លឺព្រះអាទិត្យ។

ដៃនាងម្ខាងកាន់ចានមួយមានស្លាបព្រាក្នុងនោះផង។

«ខ្ញុំមិនហូបអាហារនៅទីនេះដាច់ខាត!»

គេគិតម្នាក់ឯង ប៉ុន្តែក្រពះទាមទារបន្លឺជាសំឡេងលាយការឈឺចាប់។ នាងតូចញញឹមហើយទាញកៅអីឈើមកអង្គុយជិតនាយ។ គេក៏សម្លឹងមកនាងថ្មៃ។ គេមានកែវភ្នែកមុត ជាបុរសប្រកបដោយភាពនឹងនស្រស់សង្ហា។

ភាពជាបុរសរបស់នាយ ធ្វើឱ្យសន្យាក្រហមមុខអៀនដោយមិនធ្លាប់មានប្រតិកម្មបែបនេះពីមុនមកឡើយ។ បេះដូងនាងហាក់ញាប់ញ័រ បណ្តាលឱ្យរកនិយាយអ្វីក៏មិនត្រូវ។ ចំណែកភ្នែកគេនៅតែសម្លឹងមកនាងថ្មៃ នាងមិនដឹងទេថាព្រោះហេតុអ្វី?

«កុំមើលខ្ញុំពេកមើល៍!»

Lorenzoដឹងថានាងកំពុងច្រឡំដែលគេមើលនាងព្រោះក្តីកង្វល់ស្មានថា គេមើលនាងជារបៀបព្រាននារី បុរសក៏ងាកមកវិញយ៉ាងរហ័ស ស្រាប់តែលាន់មាត់អួយដោយ ការឈឺចាប់ព្រោះគល់កនៅមិនទាន់ជា វាទំនងជារបួសផងគ្រេចសរសៃយ៉ាងដំណំផង។

«ឱ្យតែយ៉ាងនេះ ម៉េចនឹងសង្ឃឹមចាកចេញបាន?»

គេគិតទាំងសៅហ្មង។ ភ្លាមនោះនាងដាក់ចានចុះ ហើយអោនមកពិនិត្យនាយជិតសែនជិត ធ្វើឱ្យវង់ភក្ត្រសខ្ចីនៃនារីដែលរស់នៅតែជាមួយធម្មជាតិបង្ហាញសម្ផស្សដ៏ត្រកាលក្រោមពន្លឺភ្នែកមេត្តាធម៌របស់នាង៖

«ឈឺខ្លាំងអត់?»

គេហាក់ឆ្ងល់នឹងអាការៈយកចិត្តទុកដាក់នេះ។

នាងយកដៃស្ទាបកគេត្រង់កន្លែងគ្រេច ហើយដៃម្ខាងទៀតត្រកងក្បាលគេបណ្ដោយឱ្យទ្រូងនាង បញ្ចេញសម្រស់ពីមុខនាយអាណិកជនច្បាស់ថៃសគ្មានលាក់លៀម។

ក្មេងស្រីនេះពេញក្រមុំស្គួកហើយតែនៅដៃដល់ជាមួយមនុស្សប្រុសស្និទ្ធស្នាលហាក់មិនដឹងទេថា គេកំពុងចង់គេច តែប៉ះជាមួយភ្នែកនាង នរៈចេះតែទទួលអារម្មណ៍ថា ដូចជាមនុស្សគ្មានចេតនាអាក្រក់ជាមនុស្សអាចទុកចិត្តបាន១០០ភាគរយ។

«មានប្រាប់អ្នកណាដែរអត់?»

គេសួរខ្សឹបៗឱ្យនាងដកថយមកវិញឈប់សម្លឹងកនាយបែរជាសម្លឹងមុខជំនួស។ គេធ្វើភ្នែកស្រទន់ពេលសួរនាងខ្លី ទាំងមិនដឹងទេថាសំឡេងបែបនេះ ខ្សែភ្នែកបែបនេះ វាហាក់បីដូចជាឥទ្ធិពល ដ៏អាថ៌កំបាំងរវាងភេទផ្ទុយ ដែលធ្វើឱ្យបេះដូងស្រីក្រមុំចេះលោតរន្ធត់។

នាងអៀននឹងសម្រស់ដ៏ទាក់ទាញនៃបុរសនេះ ដូច្នេះក៏បន្លប់ខ្លួនឯងជាមួយពាក្យព្ទៗ៖

«កុំតែបងឯងហាម ក៏មិនបាច់ឈើយ៉ាងហ្នឹងដែរ គេដឹកបងឯងទៅពេទ្យបាត់ហើយ! កុំអីចាក់ថ្នាំ ព្យួរសេរ៉ូមជាបាត់ហើយ»

នរៈដឹងថា នាងរក្សាសម្ដីមិនប្រាប់រឿងនាយឱ្យទៅអ្នកណាទាំងអស់ នារីនេះរស់នៅទីដាច់ស្រយាលតែមានសមានចិត្តគ្រាន់ជាងពួកអ្នកឆើតឆាយនៅទីក្រុងខ្លះដែលខ្លួនធ្លាប់បានស្គាល់។ គ្មានអ្នកណាគួរឱ្យទុកចិត្តបានម្នាក់សោះ។

គេគិតម្នាក់ឯងហើយមាត់ហាបន្ទោសតិចៗ៖

«និយាយព្ទអ៊ីចឹង អ្នកណាក៏គេដឹងដែរ!»

នារីតូចថយមកកាន់ចានបបរសាជាថ្មីហើយអង្គុយចុះក្បែរប្រាណនាយ។

«ជុំវិញនេះគ្មានមនុស្សទេ! ពួកក្មេងៗមិនមករៀនទេ ព្រោះថ្ងៃអាទិត្យ! »

គេធ្មេចភ្នែកធូរចិត្តបន្តិច។ ក្លិនចម្លែកៗធ្វើឱ្យច្រមុះគេមិនស៊ាំ។ វាមិនមែនក្លិនអាក្រក់តែគេនៅមិនសុខ។ អាណិកជនធ្លាក់ខ្លួនពោលសួរតិចៗ៖

«ខ្លួនឯងលាបអីគេលើរបួសខ្ញុំ?»

«ថ្នាំលាបរបួសសត្វសក្តិសិទ្ធិណាស់!»

គេធ្មេចភ្នែកវិញសឹងស្រែកទ្រហោយំ។

«ឱលោកម្ចាស់អើយ! ថ្ងៃអីរបស់ខ្ញុំ?»

បុរសនេះ ត្អូញផងរមួលខ្លួនតិចៗផង។

យល់ចិត្តគេនាងប្រញាប់កែពាក្យ៖

«ចង់ប្រាប់ថា វាមិនមែនជាថ្នាំសម្រាប់សត្វទេ អ្នកភូមិនេះគេប្រើសក្តិសិទ្ធិណាស់ តែខ្ញុំបុកវាទុកមកសម្រាប់ទុកបង្ការពេលសត្វមានរបួស!»

នាងថាផងពន្យល់គេផង ដៃកាន់ចាននោះស្ទើរតែមិនជាប់រកកលនឹងកំពប់។ បុរសនិយាយបន្ថែមទាំងហួសចិត្ត៖

«ហើយបបរនោះសម្រាប់សត្វដែរអត់?»

ហើយដួសបញ្ចុកម្តងនាងសម្លក់នាយដែលធ្វើមុខហាក់ខ្ពើមអាហារនាងខំចម្អិនមកដោយសុទ្ធចិត្ត។

«បងឯងមិនញ៉ាំមានតែដាច់ពោះស្លាប់! »

បុរសតបតវិញទាំងមុខជូរ៖

«មុនក្រោយគង់ស្លាប់! នាងយកថ្នាំសត្វមកបិទរបួសខ្ញុំ  អ៊ីចឹងបានពេលនេះក្រោកមិនរួច! »

ស្រីស្អាតក្តាប់មាត់និយាយតវ៉ា៖

«បងឯងមិនត្រឹមលាបទេ យប់មិញលេបទៀត! មិនអ៊ីចឹងបងឯងពេលនេះក្ដៅខ្លួនសន្លប់ លែងដឹងទិសតំបន់ហើយ! ឱ្យចេះដឹងគុណអ្នកស្រុកផង!»

អាណិកជនដ៏តម្កើងឫក មកធ្លាក់ខ្លួនព្យាបាលនៅជាយព្រៃ ពេលនេះទើបនឹងស្ដាប់យល់ថា ដោយសារថ្នាំបុរាណក្លិនចម្លែកអស់ទាំងនេះ បានជាខ្លួនអាចរួចជីវិតពីការក្ដៅសន្ធំសន្លប់ឈឹងកាលពីយប់បាន។ ឃើញថាឱសថបុរាណខ្មែរពិតជាមានប្រសិទ្ធិភាពដូចដែលអ្នកស្រុកធ្លាប់ជឿមែន។ គេបន្ថយចិត្តប្រាស់ប្រាល់វិញបានមួយកម្រិតហើយនិយាយស្រួលបួលជាងមុនមកកាន់អ្នកមានគុណតូចច្រមក់៖

«ចុះម៉េចស្នាបងហើយនឹងកបងនៅឈឺម៉េះ?»

«បងឯងគ្រេចសរសៃ ត្រូវការស្នំ! យប់មិញខ្ញុំមានតែថ្នាំក្ដៅ ឥឡូវនេះញ៉ាំបបរឱ្យហើយខ្ញុំចេញទៅរកថ្នាំស្នំ! »

គេសម្លឹងចានបបរ។ មើលទៅគ្មានអ្វីក្រៅពីអំបិលឡើយ។

ជីវិតអស្ចារ្យយ៉ាងណាហើយពេលនេះ។

«អត់ញ៉ាំបានអត់?»

នាយសួរតម្អូញ ទាំងពោះស្រេកឃ្លានតែភ្នែកមិនព្រមចង់ទទួលយកអាហារអស់នេះ ធ្វើឱ្យស្រីតូចហួសចិត្តនិយាយតបវិញចប្រែត៖

«បងឯងមិនហូបម៉េចមានកម្លាំងចេញទៅរកថ្នាំជាមួយខ្ញុំ?»

ភាគទី៤០

«អ្ហាក? ឱ្យបងទៅរកថ្នាំជាមួយខ្លួនឯង?»

ស្រីតូចងក់ក្បាលៗទាំងមុខស្មើហាក់បញ្ជាថា គេនេះមិនអាចរកលេសកម្ចិលនៅនឹងមុខនាងបានទៀតនោះទេ។

Lorenzoឆ្លើយតបទាំងហួសចិត្ត៖

«មើលចុះ! គ្រេចកងាកមិនទាំងកើតផង គេបង្ខំឱ្យទៅរកថ្នាំជាមួយទៀតនៀក? សម្លាប់ឯងទាំងរស់ហ្មងហើយ!»

នាងលែងមាត់ហើយដាក់ចានចុះពីដៃទើបអោនមករកលើកគ្រាប៍គេឡើង។

«ធ្វើអីហ្នឹង?»

បុរសភ្លាត់មាត់សួរ នាងឆ្លើយតបវិញភ្លែតៈ

«បងឯងឈឺក មែនឈឺជើងទេ! មិនឱ្យទម្រន់!»

នាងគ្រាប៍គេឱ្យក្រោក បុរសប្រឹងក្រោកតាម តែកម្លាំងនាងមិនដល់ហើយរាងកាយនាងខ្សោយជាងមាឌនាយឆ្ងាយពេក បានពាក់កណ្ដាលផ្លូវត្រូវរបូតជំហរ ដួលផ្ងារទៅវិញ អោបដោយទាំងតរុណីបុប្ផាជាយព្រៃទៅជាមួយក្នុងប្រអប់ទ្រូង។

នាងស្លុតស្មារតីពេលក្រោកមកវិញមិនរួច ព្រោះនាយច្បាមនាងតឹង។

សូរបេះដូងលោតកញ្ច្រោលរបស់ស្រីក្រមុំតូចលាន់សស្រឹបក្នុងរង្វង់ដៃឥតព្រាងទុក រួមជាមួយចំហាយក្ដៅៗរត់រសឹបពេញដងខ្លួននាងដែលកំពុងប៉ះពាល់ផ្ទាល់ជាមួយរាងកាយនាយ ធ្វើឱ្យអាណិកជនសង្ហាភ្ញាក់ខ្លួនមកវិញហើយប្រញាប់លែងដៃ។

សន្សាងើបមុខមកវិញជាមួយថ្ពាល់ទាំងសងក្រហមព្រឿងៗ ព្រោះសេចក្តីអៀនខ្មាស ចំណែកអ្នកខាងណោះក៏នឹកមានអារម្មណ៍ទើសទាល់ជាពន្លឹកដូចគ្នា គ្រាន់តែគេមានបទពិសោធន៍ជាងក្នុងការពោលបន្លប់ៈ

«ធំហើយនៅអៀនទៀត?»

នាងខំយកដៃគ្រវាសមុខខ្លួនឯង បន្លប់ដង្ហើមក្ដៅអ៊ុនៗ នោះចេញ ហើយនិយាយធ្វើខែងរ៉ែងៈ

«ពីណាអៀន?»

នាងអោនមកត្រកងគ្រាប៍នាយសាជាថ្មី ធ្វើឱ្យបុរសកាន់តែក្រហមមុខឡើងពោលរង្វ៉េវដាក់ត្រចៀកនាងៈ

«បន្តិប៉ះកូនកំលោះគេទៀតហើយឃើញអត់?»

សន្យាពោលចច្រៃតដាក់ត្រចៀកបុរសនេះវិញ៖

«បើមិនប្រឹងយោងអាត្មាក្រោកឱ្យរួចមកហូបបបរ ទុកនៅហ្នឹងឱ្យដាច់ពោះម្នាក់ឯងក្លាយជាខ្មោចគ្រេចក ងាកមិនរួច! »

នាងទាញមួយព្រឹបនាយក៏ប្រឹងមួយប្រឹបក្រោកមកបានទាំងអស់គ្នា។

អង្គុយដល់គ្រែកាលណា ប្រុសស្អាតរអ៊ូទាំងសៅហ្មង៖

«សម្ដីមហាអាក្រក់លោកយាយ!»

មុខតូចច្រឡឹងរបស់នាង ក្រញូវមិនឆ្លើយតែនាងហុចបបរទាំងស្លាបព្រាមកភ្លាមរកតែអ្នករបួសដកដង្ហើមឱ្យស្រួលក៏សឹងគ្មាន។ ចានមិនទំនងស្លាបព្រារឹតតែមិនសម សម្រាប់បុរសអ្នកមានមហាសាលដែលបរិភោគកាលណាស្គាល់តែ ពពួកចានក្បាន Brand Italia កប់មេឃ ប៉ុន្តែទឹកមុខនាងមាំពេកគេបង្ខំហាមាត់។

បបរក្ដៅៗមានរសជាតិឈ្ងុយសាយដោយធញ្ញជាតិខ្មែរផលពីធម្មជាតិសុទ្ធសាធក្លាយមកជាមានឱជារសអ្វីម្ល៉េះទេ សម្រាប់អ្នកជំងឺដ៏ខ្សត់ខ្សោយស្រេកឃ្លានក្នុងពេលនេះ។

ពីមួយស្លាបព្រាទៅមួយស្លាបព្រា គេហុតទឹកបបររាវៗក្ដៅៗនោះមួយហើយមួយទៀតភ្លេចអស់រសជាតិបណ្ដាអាហារលំដាប់កំពូលនានា ហើយទទួលអារម្មណ៍ថា  ហាក់ដូចជាមានកម្លាំងវិញបន្តិចម្ដងៗ។

សរសៃចក្ខុរបស់គេក៏បាញ់ ជះទៅរកស្រីតូច ជាសញ្ញាសម្ងាត់សម្ដែងនូវសេចក្ដីដឹងគុណយ៉ាងជ្រាលជ្រៅ។

នាងជូតមាត់ឱ្យនាយពីលើពុកចង្កាដែលមុននេះ បានបម្រុងថាកោរសំអាតតាមចរិតបុរសអភិជនដែលយកចិត្តទុកដាក់បំផុតរឿងសម្រស់និងថាមពល ប៉ុន្តែក្រោយមកបានទទួលសារអកុសលពីRoseឱ្យប្រញាប់ចាកចេញរហូតធ្លាក់ខ្លួនមកទើរលើទីជាយព្រៃមួយនេះ។

«ចាំហ្នឹងហើយ! ខ្ញុំទៅយកប្រដាប់ប្រដា យើងទៅរកថ្នាំ! »

ហួសចិត្ត។ នារីនេះតូចច្រឡឹង មានសម្ដីដូចមនុស្សចាស់ ហើយច្បាស់លាស់ការងារ ដូចអ្នកដែលមានជំនាញខាងគ្រប់គ្រង។ នាងនិយាយហើយធ្វើ ធ្វើហើយបន្តទៅមុខមិនរំលងពេលវេលាសូម្បីតែទុកពេលឱ្យអ្នករបួសបានសម្រាកចិត្តបន្តិចក៏គ្មាន។

គេនៅស្ងៀមទប់ក រវេក្នែកសម្លឹងជុំវិញខ្ទមឈើប្រក់ស្បូវដោយយឺតៗ ព្រោះសរសៃនៅធ្វើទុក្ខជាអនេក។

«អា LorenZo! ឯងដែលធ្លាប់គិតអត់ថា មានថ្ងៃណាមួយ ព្រមមកប្រើពេលវេលា មួយរាត្រីក្នុងទីកន្លែងរបៀបនេះ?»

នាងវិលមកវិញជាមួយកន្ត្រកឈើមួយពីក្រោយខ្ទងដូចជនជាតិភាគតិច។ នាយឃើញដងកាំបិតលេចស្ដឹមចេញមកពីក្នុងនោះ។ គេគិតដល់រឿងផ្សេង ។

«តើយើងពិតជាមានសុវត្ថិភាពពិតមែនឬអ្វី? មនុស្សជុំវិញយើងសុទ្ធតែជាខ្លាលាក់ក្រចក ម៉េចយើងមកទុកចិត្តមនុស្សចម្លែកដែលទើបនឹងស្គាល់គ្នាបែបនេះបាន ? ហើយប្រាកដថានាងមិននាំយើងទៅប្រហារជីវិតនៅឯណា?»

នាងបែរខ្នងប្រមូលរបស់របរខ្លះញាប់ដៃ ញាប់ជើងនាយក៏ឆ្លៀតពេលសួរស្ទាបស្ទង់៖

«ប្រញាប់ប្រញាល់ម៉េះអ្ហ៎ា?»

«សរសៃបងឯងគ្រេចខ្លាំង! ទុកចោលមួយយប់ហើយ បើពន្យារទៀតហើមជាងហ្នឹងបងឯងក្ដៅវិញ ពិបាកមើលណាស់! »

«សម្ដីមើលតែពេទ្យ!»

គេរអ៊ូរង៉ូវធ្វើឱ្យសន្យាងាកមកវិញសម្លឹង ប្រុសស្អាតដោយភ្នែកគ្រលួងៗ ទាំងសងខាងភ្លឺដូចនិលថ្ម។

«ប្រាប់ហើយថាធ្លាប់ព្យាបាលសត្វ! ព្យាបាលមិនដែលខុសទេ! »

«ហើយទុកអាមួយនេះជាសត្វដែរ?»

នាងអស់សំណើចសើចខឹកៗរវែងអន្លាយធ្វើឱ្យនាយសម្លក់នាងហើយងាកចេញទាំងទោមនស្ស។

«បងសុំទូរសព្ទប្រើតិចមក!»

នាងឆ្លើយវិញធ្វើហីៈ

«មានទូរសព្ទពីណាមក? ម្តុំៗនេះរាប់គីឡូ គ្មានសេវាទេ! ម៉េចក៏អ្នកភ្នំពេញម្នាក់ៗរស់អត់ទូរសព្ទអត់បានអ៊ីចឹង? »

ប្រុសស្អាតនៅស្ងៀមពិចារណា។

ម្តងម្កាលមុខរបួសនិងសរសៃដែលគ្រេចធ្វើទុក្ខសឹងងងឹតមុខវិញម្តងៗ។ អាណិកជនយល់ថាការពិចារណាត្អូញត្អែរច្រើន មិនអាចជួយអ្វីបានក្រៅតែពីការអត់ធ្មត់ ខំសំងំរកវិធីព្យាបាលសុខភាពឱ្យ បានល្អដូចដើមវិញសិននោះទេ។

«តោះ!»

នាងអោនមកគ្រាហ៍នាយសាជាថ្មី។

បុរសប្រឹងក្រោកហើយឃើញថារាងកាយមិនមានបញ្ហាអ្វីជាដុំកំភួន ក្រៅតែពីរឿងគ្រេចកនិងការផ្សារឈឺស្នាមដាច់រលាត់ខ្លះតែប៉ុណ្ណោះ។

ពេលនេះគេអាចដើរបាន ដោយមិនចាំបាច់មានអ្នកគ្រាហ៍ គ្រាន់តែថាឱ្យតែនរះភ្លេចខ្លួន ងាកម្តងៗ សរសៃដែលកំពុងគ្រេច ធ្វើទុក្ខឈឺពើតស្ទើរស្រែកបាន។

ទាំងពីរប្រាណចរយាត្រាចូលក្នុងព្រៃតាមលំនាំផ្លូវថ្មើរជើងតូចមួយទទឹងប្រមាណជាមួយម៉ែត្រ ហើយនាងស្គាល់ស្ទាត់ជំនាញមិនសមនឹងរូបរាងដែលតូចច្រមក់សខ្ចីដូចមនុស្សមិនដែលស្គាល់ពន្លឺថ្ងៃ។

ពន្លឺព្រះអាទិត្យបញ្ចេញរស្មីតែសីតុណ្ហភាពនៅតែស្រទន់ត្រជាក់។

កន្លែងដែលពួកគេបានដើរកាត់នៅតែស្រអាប់ងងឹតព្រោះម្លប់ឈើធំទេរមកប្រក់បាំង។ ដើរយូរបន្តិចហើយនៅតែមិនដឹងនាងចង់ធ្វើអ្វីឱ្យប្រាកដ បុរសអាណិកជនបង្ហើរសំឡេងសួរៈ

«ទៅឆ្ងាយអត់ហ្នឹង?»

គេសួរព្រោះម្តងម្កាល កនិងស្មា រើសេចក្តីឈឺចាប់ ហើយរោយជើងដៃ ព្រោះទើបនឹងរួចពីការឡើងកម្តៅពេញមួយយប់។

«ជិតហ្នឹង! ដើរប្អូនដប់នាទីទៀតរកឃើញហើយ! »

នាងឆ្លើយ តាមសម្រួលតែចិត្តនាយកំពុងនឹកសង្ស័យថាតើនាងពិតជា កំពុងស្វែងរករុក្ខជាតិមកដោះស្រាយការគ្រេចថ្លោះនេះ មែនឬអ្វីផ្សេង? បើពឹងលើសម្តីនាង ស្រីតូចនេះទំនងចេះចាំស្គាល់ច្បាស់បណ្តាឱសថធម្មជាតិផងទាំងឡាយ ។

គេនឹកក្នុងចិត្តជាសម្ងាត់ថា ហោចណាស់ពេលនេះក៏ទុកថាល្អដែរ ដែលអាចនឹងគេចចេញពីពួកមនុស្សមិនល្អមិនស្គាល់មុខមាត់អស់ទាំងនោះមួយគ្រា។ ទីនេះកាន់តែឆ្ងាយកាន់តែអំណោយផលគ្មានអ្នកណាចាប់អារម្មណ៍មកលុកលុយរកដល់។

សំឡេងនាងដែលដើរចោលនាយនៅខាងមុខប្រមាណ៥ម៉ែត្រនិយាយមកឮៗ៖

«ខ្ញុំចង់មានពេលមកកន្លែងនេះយូរហើយតែគ្មានគ្នាមកជាមួយ! នៅមុខបន្តិចមានកន្លែងសក្តិសិទ្ធិមួយ ខ្ញុំអាចឆ្លៀតពេលបន់ស្រន់ល្មម!»

«បន់ស្រន់?»

គេសួរមកល្ងើយៗ។ សន្សាដើរផងងាកមើលឆ្វេងស្តាំផងចិត្តនឹករលឹកទៅដល់សម្តីបងធម៌ឈ្មោះឈុនរាជនោះផង។ នាងឆ្លើយទាំងញញឹម ៖

«ខ្ញុំសង្ឃឹមថា ថ្ងៃណាមួយម្នាក់ឈ្មោះ Lorenzo នោះនឹងមកកាត់កន្លែងខ្ញុំ!»

ស្ងាត់ច្រៀបគ្មានសំឡេងតប នាងនិយាយបន្តដោយរីករាយ៖

«គេជាអ្នកមាន ហើយជាតារាសប្បុរស! គេនោះប្រាកដជាមកជួយកសាងអណ្តូងទឹកឱ្យអ្នកស្រុកព្រៃខាងជើងហើយជួយសង់សាលាឱ្យផ្ទះអនាគត!»

នៅតែមិនឮចម្លើយនាងកើតចិត្តឆ្ងល់។

ស្រីតូច បែរក្រោយហើយឃើញអ្នករបួសនៅទ្រឹងហើយឈប់ដើរមកតាម។ គេនៅឃ្លាតឆ្ងាយយ៉ាងនេះ នាងគិតថាគេដើរហត់កើតខ្ជិល តែមិនដឹងឡើយថាគេស្លុតដែលឮនាងនិយាយចំឈ្មោះខ្លួនឯង។

«បងឯងមិនប្រឹងដើរឱ្យរហ័សបន្តិចមក! តែភ្លៀងហ្នឹងពិបាករកកន្លែងជ្រកអត់បាន!»

«មិញនេះ ខ្លួនឯងនិយាយថាម៉េច? ខ្លួនឯងហៅឈ្មោះពីណាគេ?»

នាងរកនឹក ព្រោះបើនិយាយហើយក៏ចោលទៅបាត់ហើយមិនបានចងចាំច្រើនទេ ពេលគេសួរមកវិញហាក់មាំទាំនាងក៏រឹតតែឆ្ងល់។

«ខ្ញុំនិយាយអីគេ?»

«អ្នកណា? មិញខ្លួនឯងបន់ស្រន់ចង់ជួបអ្នកណា?»

សន្យាសម្លក់គេថ្មៃ ទាំងឆ្ងៀតលួចគិតស្ងាត់ៗ «ស្អីគេទើបនឹងស្គាល់គ្នាមកចេះប្រចណ្ឌ?»។ ប្រុសស្អាតមិនដឹងឡើយថានៅសុខៗមកជួបគ្រោះធំ ឥឡូវតាមពីក្រោយស្រីម្នាក់មានលាក់កាំបិតចូលក្នុងព្រៃជ្រៅទៀត  នាងមកនិយាយឈ្មោះខ្លួនកណ្ដាលផ្លូវមិនឱ្យLorenzoប្រហោងពោះ។

«Lorenzoហ្នឹងអ្វី ? ឈ្មោះចម្លែករបស់គេហ្នឹងអ្វីធ្វើឱ្យបងឯងឆ្ងល់?»

គេមិនព្រមដើរមកថែមសោះគិតពីតាមដានទឹកមុខនាងភ្លឹះៗ។

នារីនេះមើលពីឆ្វេងពីស្ដាំមើលឬកពានាងចុះឡើងមើលយ៉ាងណាក៏មិនទំនងដឹងសមាសភាពរបស់ខ្លួនដែរ តែហេតុអ្វីនាងហៅឈ្មោះខ្លួនច្បាស់ ហើយបន់ស្រន់ជួបខ្លួនដោយសារអី ? អ្នកណាម្នាក់ប្រើនាងឱ្យមានបំណងអាក្រក់អ្វីម្យ៉ាងលើឈ្មោះនេះគ្រាន់តែនាងមិនស្គាល់រូបរាង?

មានតែឈ្លេចសួរទើបជាមធ្យោបាយល្អ។

នៅខាងមុខ ស្រីស្អាតច្រត់ចង្កេះសៅហ្មងដែលឃើញបុរសនេះនៅដំអក់មិនព្រមដើរមកទៀត។ គេឃើញដូច្នេះឆ្លើយស្រែកសួរពីចម្ងាយភ្លាម៖

«បានឈ្មោះនេះមកពីណា?»

នាងក្រញូវមិនព្រមឆ្លើយបុរសនេះដើរមួយៗទៅកៀកនាងហើយសួរទៀត៖

«ឮសួរអត់? ម្នាក់ដែលខ្លួនឯងចង់ជួបហ្នឹង ស្គាល់ឈ្មោះគេមកតាមរបៀបណា? ហើយជួបគេមានការអី?»

ស្រីតូចក្របួចមាត់រអ៊ូ៖

«ខ្ញុំស្មានបងឯងអ្នកនៅភ្នំពេញដឹងរឿងច្រើនជាងខ្ញុំ ដឹងអី បងឯងយ៉ាប់ជាខ្ញុំមួយយោជន៍!»

«ស្អីទៅមួយយោជន៍?»

«អូ្ហយ! ខ្មែរក៏មិនចេះ? រៀនបានថ្នាក់ទីប៉ុន្មាន?»

«យប់មិញ ខ្លួនឯងសរសើរថាបងមានក្លិនទឹកអប់ជាអ្នកភ្នំពេញ?»

គេតវ៉ាព្រោះហួសចិត្តដែលត្រូវស្រីច្រមក់មកនិយាយមើលស្រាល។

សន្សាជ្រួញចិញ្ចើមតបវិញមិនបង្អង់៖

«ទឹកអប់អាចលួចគេលាប! មានអីសម្គាល់ថាអស្ចារ្យទេ! ឥឡូវប្រាប់មក បងឯងមកពីណា? មានប្រភពមកពីកន្លែងណា? ម៉េចមកបង្ហាញមុខម៉ុំៗនេះ? អូ្ហយខ្ញុំនេះភ្លេចគិត ពាក្យចាស់គេថា មនុស្សខ្វាត់ភ្លាត់ មិនដឹងប្រវត្តិត្រូវប្រយ័ត្ន ដូចជាចង់ជ្រុលក្បាលក្រពើហើយខ្ញុំនៀក!»

ដល់វេនខាងប្រុសច្រត់ចង្កេះវិញម្តង។

ដែលហួសចិត្តបំផុតគឺពាក្យទាំងប៉ុន្មានឃ្លាចុងក្រោយនេះ។ នាង និងគេ តើអ្នកណាខ្វាត់ភ្លាត់ឱ្យប្រាកដទៅនៀក? អ្នកប្រុសគិតទាំងក្តៅចិត្ត តែគេខ្ញុំទប់ហើយស៊ើបសួរបន្តទាំងសៅហ្មង៖

«សួរថា អាឈ្មោះLorenzoហ្នឹងអ្នកណាប្រាប់ខ្លួនឯង? ស្គាល់ឈ្មោះនេះពីណាមកក្មេងមាត់ដាច?!»

ខំព្យាបាលរបួសឱ្យមិនដេកពួនទម្រាំគេអាចបញ្ចុះកម្តៅបាន ឥឡូវមកឈរច្រត់ចង្កេះដាក់ឈ្មោះថ្មីឱ្យខ្លួនតាមទំនើងចិត្តទៀត នាងក៏ស្រែកដាក់វិញ៖

«សង្សារខ្ញុំ! ម៉េច? អស់ចិត្តឬនៅ? »

ថាហើយនាងដោះកន្ត្រកបោះចុះដីហើយចាប់ផ្តើមរើកាំបិតចេញមកជីកគាស់។ ស្រីស្អាតជីកដើមរុក្ខជាតិមកព្យាបាលឱ្យនាយ មិនទាំងចាប់អារម្មណ៍ឡើយថាពាក្យចុងក្រោយរបស់ខ្លួនឯងធ្វើឱ្យអ្នកប្រុសធ្លាយសំណើច។

គេក្រពាត់ដៃត្រវីក្បាលព្រោះអស់ពាក្យនិយាយ ដឹងអីកគ្រេចបន្តឈីធ្វើមុខជូរសើចលែងសម។

នាងបានរុក្ខជាតិកាលណារើដបទឹកក្រហមត្លៃ និងត្បាល់បុកមួយចេញពីក្នុងកន្ត្រក។

មិននឹកស្មានថា នាងលើករបស់ច្រើនយ៉ាងនេះធ្ងន់យ៉ាងនេះហើយដើរមកបានឆ្ងាយយ៉ាងនេះ មិនត្អូញត្អែរអ្វីថែមទាំងត្រូវខ្លួនស្ដីថាឱ្យទៀត?

មើលរាងនាងដែលអង្គុយចិញ្ច្រាំថ្នាំដាក់ត្បាល់គួរឱ្យអាណិត ។ អាណិកជនភ្លេចអស់ការទើសទ័លនិងសម្ដីផងទាំងឡាយក៏ចូលទៅក្បែរហើយអង្គុយចុះជិតនាង។

នាងព្មដង្ហើមនាយតែនាងធ្វើហីមិនខ្វីនិយាយ មិនខ្វីងាក ចាប់ផ្ដើមបុកពួករុក្ខជាតិបញ្ចូលគ្នា។

«សុំទោសបានអត់?»

«មនុស្សខ្ញុំមិនចេះខឹងទេ!»

នាងឆ្លើយយ៉ាងរត់មាត់តែមុខនាងខឹងច្បាស់ក្រឡែត។

«Lorenzoតារាសប្បុរសល្បីនៅភ្នំពេញហ្នឹងមែនអត់ជាសង្សារខ្លួនឯង!»

គេនឹកឃើញនិយាយលេងបន្លប់បរិយាកាសគ្រោតគ្រាត មិនស្មានដល់ទេថា ឈ្មោះបីម៉ាត់នេះអាចនាំនាងឱ្យសើចវិញបានសោះ។ ស្រីតូចញញឹមចិញ្ច្រាចបញ្ចេញសម្រស់ត្រដែតជាមួយធ្មេញទាំងជួរសដូចម្លិះ។

«ស្គាល់គាត់ដែរ?»

នាងងាកមកនិយាយភ្លាមៗធ្វើឱ្យប្រុសស្អាតភ័ន្តភាំង។ គេនៅទ្រឹងសម្លឹងប្រតិកម្មពេញដោយភាពរំភើបលើផ្ទៃមុខដែលមានទម្រង់ទ្រវែង ហ្មត់ហ្មងគ្មានសូម្បីស្នាមផុលរមាស់អ្វីមួយ។

សក់នារីនេះវែងអន្លាយខ្មៅរលោងរលាស់ពេញដោយជីវិតជីវ៉ា ហើយចុងសក់ប៉ប្រះថ្ពាល់នាងក៏បក់រវិចចុះឡើងទៅតាមកិរិយាជ្រួលច្របល់នៃម្ចាស់វា។

គេទ្រាំមិនបាននឹងអាការៈស្រីតូចនេះ ក៏សួរបកទៅវិញទាំងជ្រួញចិញ្ចើម៖

«ហើយមានទំនាក់ទំនងអីនឹងម្នាក់នោះ?»

«ខ្ញុំសួរថាបងឯងម៉េចបានស្គាល់គាត់!»

គេចាប់ផ្ដើមងាកមកប្រយ័ត្នសមាសភាពខ្លួនឡើងវិញ ហើយរកពាក្យនិយាយបង្វែងឆ្ងាយពីប្រភពពិតរបស់ខ្លួន៖

«កាលនៅលើទូក ពួកកម្មករនេសាទជាមួយគ្នាគេធ្លាប់និយាយឱ្យស្ដាប់ថាម្នាក់នោះជាអ្នកមានល្បីនៅភ្នំពេញ!»

នាងឮថានាយជាកម្មករក៏ឈប់ដៃ ឆ្លោយសម្លឹងពិនិត្យនាយយើងសាជាថ្មីពីលើចុះក្រោម ធ្វើឱ្យទេវបុត្រសេះស រឹតតែបានចិត្តនិយាយកុហកបន្ថែមរួដូចទឹក៖

«បងឯណាដែលបានទៅភ្នំពេញ? មិនដឹងទីក្រុងបែរទៅណាផង! មួយជីវិតនេះដើរតែធ្វើការឱ្យគេលើទូក!»

នាងជ្រួញចិញ្ចើមនិយាយ៖

«អ៊ីចឹងបានដៃជើងបងឯងមើលទៅមនុស្សលំបាកហ្មងហ្នឹង!»

ស្រីស្អាតនេះព្យាយាមធ្វើចរិតដូចជាខ្លួនឯងជាមនុស្សឆ្លាត Lorenzoដឹងអ៊ីចឹងបានជានាយមិនខ្វីប្រកាន់ខឹង។ នៅតែបន្តិចទៀតនាងអាចនឹងដូរពីពាក្យ «លំបាក» មកជា «ក្រ» តែម្ដងក៏ថាបានមនុស្សមាត់ដាចដូចនាង។

មុននេះនាងទាយថាគេជាអ្នកភ្នំពេញ ពេលនេះឮប្រវត្តិជាកម្មករក៏និយាយចាក់បណ្ដោយខ្លាចគេថាខ្លួនមិនពូកែសង្កេតមើល។

បុរសញញឹម ភ្លេចការឈឺចាប់។

លើលោកនេះមនុស្សស្រីគេជួបច្រើនហើយ។ នារីអភិជន មិនថាឆ្នាំនាគ ឬមិនមែន ឱ្យតែគេប៉ង សុទ្ធតែបានអង្គុយទល់មុខក្រោមភ្លើងទានជាមួយគ្នាម្នាក់ៗញញឹមញញែមយកចិត្តគេ  មិនសមថាពេលនេះមកអង្គុយកណ្ដាលផ្លូវកណ្ដាលព្រៃក្លែងខ្លួនជាអ្នកនេសាទកម្សត់ឱ្យស្រីច្រមក់ម្នាក់មើលងាយកាយសម្បទារបស់គេសោះ។

«ហើយបងLorenzoរបស់ខ្លួនឯង ស្អាតសង្ហាប៉ុនណាទៅអ្ហះ?»

គេខ្សឹបសួរពេលដៃនាងតូចកំពុងបុកថ្នាំប៉ូកៗ ហើយបបូរមាត់នាងញញឹម ពណ៌ក្រពុំឈូក។

ភាគទី៤១

«មិនដែលឃើញមុខទេ ឮតែឈ្មោះគាត់!»

នាងឆ្លើយធ្វើហីហើយបុកថ្នាំបន្ត។ បុរសអាណិកជនយល់ថានាងតូចនេះអាល័យតែមានអារម្មណ៍ខ្លាំងពេលនិយាយរំលឹកអំពីឈ្មោះរបស់អ្នកមាននៅឯទីក្រុង ទើបមិនបានមកនឹកខ្វល់សូម្បីតែនឹងសួរថា កម្មករនេសាទម្នាក់នេះធ្វើដូចម្តេចក៏រសាត់អណ្តែតមកដល់ទីនេះ?

គេឃើញនារីតូចនេះលាយល្បាយជាច្រើនបញ្ចូលគ្នា ខ្លះជាវត្ថុរាវខ្លះជាម្សៅហើយខ្លះទៀតជារុក្ខជាតិដែលនាងទើបនឹងជីកបាន។ ទោះយ៉ាងណាពេលនេះអាណិកជន ចាប់អារម្មណ៍ខ្ពស់តែអំពី រឿងថា នាងហេតុអ្វីស្គាល់ឈ្មោះខ្លួនហើយអួតខ្លួនជាសង្សារទាំងដែលមិនធ្លាប់ឃើញមុខគ្នាម្តងសោះ។

«មានសង្សារមិនឃើញមុខគ្នាដែរ? ខ្លួនឯងដឹងថាសង្សារគេសំដៅលើអីអត់?»

ម្តងៗគេសឹងតែច្រឡំប្រើពាក្យនៅអាមេរិក ហើយចង់និយាយថា នៅលោកខាងលិចគឺពាក្យសង្សារគេសំដៅលើមនុស្សបានគេងជាមួយគ្នា ដោះដូរខ្លួនប្រាណជាមួយគ្នាដែលនាងមិនសមយកមកប្រើស្លុយៗបែបនេះទេ។ ចំណែកនាងមើលទៅដូចកុលាបក្នុងទងក្រពុំ សូម្បីតែរីកក៏មិនទាន់រីកគ្រប់ស្រទាប់ផង។

ប្រុសម្នាក់នេះរេភ្នែកលួចពិនិត្យរាងកាយនាងពីលើដល់ក្រោម។ ក្រៅពីដើមទ្រូងពើងខ្ពស់ជំទើត លាក់ក្នុងអាវរបស់នាង សន្សាថែមទាំងអង្គុយខ្មៅតចង្កេះជាមួយត្រគាករីកសាយ។ បុរសអភិជនស្រមៃនឹកឃើញ ប្រសិននាងបែរជាស្ថិតក្នុងលំដាប់អាវរាត្រីម៉ាកNatoriអ្វីទាំងពួងនោះវិញ ពួកអភិជនស្រីៗដែលបានណាត់ជួបអាចថាគ្មានអ្វីលើសស្រីច្រមក់នេះផងក៏ថាបាន។

នាងនិយាយចប្រែចៗតមិនមានរវល់នឹងកែវភ្នែកបុរសសម្បូរស្នេហ៍៖

«ខ្ញុំកុហកក៏បងឯងជឿដែរ?»

គេហួសចិត្តដែលនាងគិតថាគេព្រមជឿ។ ទោះយ៉ាងណាក៏ដោយ សម្តែងល្ខោនគួរតែសម្តែងឱ្យចប់ចុងចប់ដើម។

«ចុះមុននេះ អ្នកណាថាបន់ស្រន់ ឱ្យជួបគេ?»

សន្យាឆ្លើយតបទាំងមិនបានងើបមុខមកសម្លឹងនាយ៖

«ខ្ញុំកំពុងចង់ជួបគេដើម្បីសុំជំនួយ!»

នឹកដល់រឿងជំនួយ បុរសអ្នកមានធ្វើមុខស្មើ។ ចរិតរបស់គេមិនចូលចិត្តស្រាប់ហើយពួកមនុស្សដែលស្រើបស្រាលនឹងការមានបានហើយរស់នៅរំពឹងតែលើការហុចដៃសុំជំនួយអំពីអ្នកដទៃ។

គេស្ដីបន្ទោសភ្លាម៖

«មានដៃពីរជើងពីរ មិនចេះធ្វើការចេះតែសុំគេ !»

នារីតូចងើបមុខមកវិញសម្លក់នាយហើយនិយាយផ្ទូង៖

«អ៊ីចឹងបងឯងមកសន្យាភ្លាម ថាឱ្យតែជាកាលណា ត្រូវនៅហ្នឹង ជួយជីកអណ្ដូងទឹកឱ្យខ្ញុំឱ្យបាន៧៨អណ្ដូង!»

គេបើកភ្នែកធំៗ។

នាងធ្វើរញ៉ុំរញ៉ូវទាញអាវនាយដោះធ្វើឱ្យនាយភ័ន្តភាំងប្រកែករាដៃ។

«អ្នកស្រុកនេះគេខឹងម្ដងៗរ៉ៃដោះអាវហ្មែន?»

សន្យាគក់បុរសនេះ ផាច់ៗ ទាំងដែលគ្នានៅសើចតាមសម្លឹងមើលកណ្ដាប់ដៃនាង។

«មនុស្សកំពុងគ្រេចក!»

គេនិយាយទាំងសើចក្អាកក្អាយ។

«បើមិនដោះអាវលាបថ្នាំម៉េចអាឡូវ?»

ទេវបុត្រញញឹមនៅសំងំស្ងៀមឱ្យបុប្ផាជាយព្រៃ ដោះអាវគេម្ខាងទម្លាក់សំយេះចេញហើយបណ្ដោយឱ្យនាងយកល្បាយដែលបុកហើយសើមស្អិតនោះមកប៉ាត់លាបដោយម្រាមនាងផ្ទាល់លើកញ្ចឹងកនិងស្មាឆ្វេង។

ស្រីស្អាតនៅស្ងាត់ស្ងៀមតែគេដឹងថានាងកំពុងប្រឹងធ្វើទាំងអៀនប្រៀននឹងរាងកាយជាប្រុសស្អាតរបស់ខ្លួនបានជានៅស្ងាត់មាត់ដូច្នោះ។

គេចាប់ផ្ដើមបានចិត្តនិយាយចំអន់៖

«បើបងកម្មករម្នាក់នេះនិងអាម្នាក់Lorenzoនោះមកឈរទន្ទឹមគ្នាឱ្យរើស ខ្លួនឯងរើសយកមួយណាអ្នកគ្រូពេទ្យ?»

នាងអាចមើលឃើញស្នាមញញឹមស្រស់បំព្រងរបស់បុរសនេះជាលើកដំបូង ព្រោះកាលពីយប់រហូតដល់ភ្លឺក្រៅពីតម្កើងឫកធ្វើដូចអ្នកអង្គម្ចាស់ គេមិនបានឱ្យនាងសូម្បីតែកែវភ្នែកស្រទន់មួយក្រឡេក កុំថាដល់ទៅញញឹមបង្អួតភាពជាបុរសរបស់គេដូចក្នុងពេលនេះ។

ទោះយ៉ាងណាពេលមានអារម្មណ៍កាន់តែចាញ់ប្រៀបលើរូបសម្រស់គេ នាងក៏កាន់តែចេះប្រុងប្រយ័ត្នក្រែងភ្លាត់ឱ្យគេដឹងចិត្តខ្លួនដែលកំពុងគិតអ្វីចំពោះចំហាយស្នេហ៍នៃភាពជាបុរសពេញលក្ខណៈរបស់គេ។

តូចតន់ឆ្លើយបន្ទន់សំឡេងតែពង្វាងអត្ថន័យ៖

«អ្នកណាក៏ដោយ ឱ្យតែមានអណ្ដូងឱ្យ៧៨!»

«ស្អីគេ យកមកធ្វើអីច្រើនម្ល៉េះ?»

«ខ្ញុំដឹងអ្នកនិយាយហ្នឹងគ្មានលុយហើយ!!! តែមិញអ្នកណាអួតថាមានដៃពីរមិនបាច់សុំគេ! ចាំមើលអ្នកពូកែហ្នឹងជីកបានប៉ុន្មានអណ្ដូង?»

បុរសញញឹម នាងអោនទៅលើកយកកម្ទេចដៃអាវគេដែលរហែកទើរលើមែកឈើកាលពីយប់មករុំរបួសព័ទ្ធទៅក្រោយឱ្យហាក់ស្អាត់ជំនាញ។

«ហើយរត់ទៅកន្លែងហ្នឹងយកអាវរហែកមកវិញបានទៀត?»

នាងនៅចងអាវមុខស្មើមិននិយាយមិនឱ្យគេចាប់ថ្នាក់ការកម្រើកនៃបេះដូងបានទេ។

ឯខាងបុរសគិតពីញ៉ោះមិនឈប់៖

«យប់ងងឹតនៅហ៊ានទៅទៀត ហ៊ានណាស់ហ្ន៎អត់ខ្លាចទេ!»

«រឿងដែលខ្លួនមិនដឹងមានច្រើនជាងហ្នឹងទៀត! »

ស្រីតូចប្តូរពីពាក្យបងមកជា«ខ្លួន»គឺនាងនិយាយតាមពាក្យគេ ដែលហៅនាងដូច្នេះ។ ក្នុងការសង្កេតរបស់Lorenzo នារីនេះចម្លងគេបានយ៉ាងរហ័សដូចម៉ាស៊ីនកុំព្យូទ័រ នាងពិតជាមានភាពវ័យឆ្លាតតែហេតុអ្វីបានជានាងមានជីវិតរបស់នាងនៅអាថ៌កំបាំងហើយស្ងប់ស្ងាត់បែបនេះ?

គេគិតម្នាក់ឯងក្នុងចិត្ត.....

**វគ្គ អវសានវាទរបស់ Roy**

នេះជាពែងកាហ្វេទីបីហើយ ទ្រនិចនាឡិកាក៏ចង្អុលដល់ម៉ោង១រំលងអធ្រាត្រហើយដែរ។

«ឯងមិនគិតដេកពួនទេអាស្នងការជិតរបូតមួក?»

គេគិតទាំងភ្នែកស្វាងថៃសតែអារម្មណ៍បាក់ស្រឹបទៅក្នុងរលកប្រស្នារាប់រយស្រទាប់។ កាន់តែដោះ កាន់តែជំពាក់ កាន់តែប្រឹងហែលកាន់តែលង់។

«ដកថយមកវិញ ហើយទុកចន្លោះដកដង្ហើមមួយសិនអាRoy!»

គេប្រាប់ខ្លួនឯងទាំងលើកដៃញីថ្ងាស។

ជីវិតជានិស្សិតខ្មែរ ខ្សោយភាសា គ្មានមិត្តហើយរៀនឡើងយកមុខវិជ្ជាមហាយ៉ាប់នៅស្រុកត្រជាក់ មនុស្សម្នាគ្មានមនោសញ្ចេតនា ដើរកុបៗ លឿនៗ ប្រេនៗ ហើយគ្មានស្គាល់ពាក្យថា«អ្នកណាជួយអ្នកណា?».

ដើម្បីគោលដៅកូនប្រុស រៀនដូចមនុស្សឆ្កួតចិត្ត មិនស្គាល់យប់ថ្ងៃ រហូតការពារនិក្ខេបបទបានលេខមួយ វិលមកស្រុកមិនបានប៉ុន្មានចាប់ចោរ  បំបែកក្តីមិនចេះតិច ជីវិតផ្សងមុខគំនុំនៃមនុស្សក្រៅច្បាប់ មិនដែលគិតពីសុវត្ថិភាពផ្ទាល់ខ្លួន ទម្រាំបានផ្កាយមកពាក់ ហើយចុងក្រោយ បានពាក់មួកគ្រប់គ្រងទីក្រុងធំមួយ បេះដូងនៃកម្ពុជា។ អ្នកមិនដឹងរឿង ឃើញមុខមាត់បុរសនេះនៅក្មេងសេចក្តី គ្រួសារមានលុយកាក់ក៏ត្មះដៀលពីក្រោយថាឡើងតំណែងតាមខ្សែ ប្រើអំណាចគ្រួសារ។

ថ្ងៃនេះ ម៉ោងនេះទៀតសោត អាចោលម្សៀតណាម្នាក់ បានរៀបគម្រោងការមនុស្សស្រីកើតឆ្នាំ២០០០ហើយ៣៥នាក់នេះឡើងមក គួរហៅវាថាជាគម្រោងការសម្លាប់មួយដើម្បីដោះម្ជូកឯងហើយអាRoy គឺដោះយកទៅបោះចោលក្នុងលូទឹកស្អុយ ចំណែកឯងវិញធ្វើរណោះអវសានវាទ ជិតចូលមកដល់ នៅបន្តអង្គុយសំកុករង់ចាំពួកកាសែតសំលៀងដែលសរសេរជាន់ពន្លិចបន្ថែមទុកឱ្យសាធារណៈ មតិ សើចលេងកម្សាន្តចិត្ត ទាំងខ្លួនឯងផ្ទាល់មិនដឹងសូម្បីតែស្រមោលអាមួយនោះវាជាអ្នកណា ក្មេងចាស់ស្រីប្រុស ហេតុអីក្រឡាសំណាញ់វាញឹកមិនឱ្យរបូតមកសូម្បីតែកូនត្រីល្អិតជាតម្រុយតូចមួយ?

ឯងជាអ្នកណាអាកំសាក! ឯងវ៉ៃអញពីក្រោយ ឯងជាប្រុសស្រីឬខ្ទើយ?

សម្តីមនុស្សស្រីដែលគេបានបាក់ចិត្តស្រលាញ់ជាស្នេហាពិតក្នុងជីវិតនេះលាន់មកវាយដំប្រអប់បេះដូងម្តងហើយម្តងទៀត «រឿងក្តីដែលលោកកំពុងធ្វើ វាមហាស្មុគលោកទៅធ្វើទៅRoy ហើយប្រយ័ត្នខ្លួនផង ពួកប៉ូលិសអស់នោះរួមទាំងប៉ាក្មេករបស់លោកផង គ្មានបានការទេ!»

នាងដៀលប៉ូលិសគឺដៀលខ្ញុំណាRose ខ្ញុំសមណាស់នឹងឱ្យនាងដៀល?

គេក្រោកឈរសម្លឹងទៅក្រៅបង្អួច។

រាជធានីនៃព្រះរាជាណាចក្រសុខដុមរមនានេះមិនមានកំពូលជើងឆើតបណ្តាញកុំព្យូទ័រ ឬពពួកអ្នកស៊ើបអាជីពច្រើនដូចនៅជម្រកពួកលោកខាងលិចដែលគេធ្លាប់ជ្រកកោនរៀនសូត្រតែRoyមិនព្រមជឿទេថា មនុស្សគំនិតអាក្រក់ទាំងនេះអាចសំងំសុខរហូតទៅ។

«ឯងឈ្មោះបណ្តោះអាសន្នប៉ុណ្ណោះអាកំសាកញី! »

ស្នូរកុំព្យូទ័រទាញគេឱ្យបែរក្រោយ។

មនុស្សជំនិតផ្ញើរបាយការណ៍មក។ Royប្រញាប់ងាកមកហើយអោនអានវាដោយយកចិត្ត

ទុកដាក់។

«លំហូរលុយរបស់គ្រួសារតាពាង តាមពិតពុំមែនត្រូវល្បែងទេ! គាត់បានទទួលលុយបួនលើកពីមនុស្សបួននាក់ខុសគ្នា ដែលជាបុគ្គលិករបស់ក្រុមហ៊ុនសេវាកម្មផ្នែកច្បាប់មួយឈ្មោះ

Legal Gem ម្ចាស់ក្រុមហ៊ុនឈ្មោះ សូត្រនិស្ស័យ មុខរបរជា មេធាវីមានប្រវត្តិមកពីសហរដ្ឋអាមេរិក រៀបការជាមួយអតីតប៉ូលិសចូលនិវត្តន៍ឈ្មោះ សេតវិទូ មានកូនប្រុសម្នាក់អាយុ៤ឆ្នាំ!»

Royលើកម្រាមដៃមកខាំតិចៗ។

«សេតវិទូ?»

សំណុំឯកសារមួយផ្សេងទៀតលោតមកដល់។ ភ្នែកគេស្វាងថៃសប្រញាប់ចុចបើកមើល។

«ទំនាក់ទំនងរវាងគ្រួសារមេធាវីសូត្រនិស្ស័យនិងសេតវិទូជាមួយតារាសប្បុរសLorenzoមានភាពប្រទាក់ក្រឡាស្មុគស្មាញ! កាលពីច្រើនឆ្នាំមុន មេធាវីសូត្រនិស្ស័យធ្លាប់មានប្រវត្តិជាមិត្តស្រីរបស់ប៉ាគេ គឺមេធាវីការពារឧក្រិដ្ឋជននៅអាមេរិកឈ្មោះជំនិត! ពួកគេបែកបាក់គ្នាហើយក្រោយមកមេធាវីជំនិតបានរៀបការជាមួយអតីតគូដណ្តឹងសេតវិទូ ឈ្មោះភីណាជាកូនស្រីអ្នកមានកំពូលនៅភ្នំពេញ!

កាលពី១០ឆ្នាំមុនដែលមេធាវីជំនិតត្រឡប់មកកម្ពុជា គេប៊ិះនឹងរើខ្លួនមិនរួចនៅក្នុងករណីឃាតកម្មលើអ្នកបញ្ចូលភ្លេងទូរសព្ទឈ្មោះណិច នៅសង្កាត់ស្ទឹងហាវក្រុងព្រះសីហនុ កុំតែបាន សេតវិទូនិងប៉ូលិសមូលដ្ឋានឈ្មោះសារឿនជាអ្នកបំបែកក្តីឱ្យ! ឮថាសំណុំរឿងនោះមហាស្មុគទាក់ទិននិងFolderគីមីពុលមួយឈ្មោះz22 ក្តីនេះនៅតម្កល់ទុកជាឯកសារផ្នែកព្រហ្មទណ្ឌនៅឡើយ! ក្រោយមកពួកគេបានរាប់អានគ្នាហើយមេធាវីជំនិតចាកចេញទៅអាមេរិកជាមួយភរិយាមិនដែលវិលមកលេងភ្នំពេញឡើយ! មានឯកសារថា ជំនិតវីរៈ ជាកូនធម៌កំព្រាឪពុកម្តាយក្លាយមកជាកូនសំណព្វស្នងមរតកសព្វបែបយ៉ាងទាំងខាងឪពុកទាំងខាងម្តាយទាំងនៅអាមេរិកនិងភ្នំពេញ! គេមានឈ្មោះក្រៅថាLorenzo!»

Roy ភ្នែកគិត ហើយអង្គុយប៉ុកមកលើកៅអីធ្វើការវិញ។

«ឆែកបានតែប៉ុណ្ណឹង?»

ដៃគេចុចសួរ ឬងអ្នកម្ខាងទៀតហាក់នៅអនឡាញនៅឡើយនោះតបមកវិញយ៉ាងរហ័សៈ

«រកឃើញអីថ្មីទៀតខ្ញុំនឹងជម្រាបលោកភ្លាម!»

«អូខេអរគុណ!»

គេចុចសញ្ញាលាពីអ្នកដែលរាយការណ៍ ហើយរួសរាន់ភ្ជាប់ឆាតទៅនឹងអ្នកផ្សេងម្នាក់ទៀតភ្លាមតែម្តង។ អ្នកនោះឯងក៏ភ្ជាប់មកវិញរហ័សដូចផ្លេកបន្ទោរ ៖

«សូមគោរពស្នងការ!»

Royសរសេរញាប់ដៃស្មេរះ

«រកអ្នកស៊ើបណាម្នាក់នៅអាមេរិកដែលធ្វើការល្អ ខ្ញុំចាយលុយខ្លះហើយចង់ដឹងពីរឿងរ៉ាវសំខាន់ៗរបស់គ្រួសារមេធាវីម្នាក់ឈ្មោះជំនិត ភរិយាគេឈ្មោះភីណា! រយៈពេល១០ឆ្នាំដែលគេវិលពីកម្ពុជាទៅអាមេរិកវិញ ខ្ញុំចង់ដឹងថាមានរឿងអ្វីខ្លះកើតឡើងចំពោះពួកគេ រួមទាំងកូនធម៌របស់ពួកគេឈ្មោះLorenzoផង! អូច្រឡំ ឈ្មោះក្នុងប៉ាសស្ព័រគេ ជំនិតវីរៈ»

«បាទទាន! ខ្ញុំទៅធ្វើភ្លាម!»

គេផ្តាច់ហើយងាកទៅឆាតផ្សេងទៀត។

«ពៅ!»

«បាទមេ!»

អ្នកម្ខាងទៀតឆាតមកវិញហាក់ប្រចាំការ ចាំតែទទួលបញ្ជា ធ្វើឱ្យRoyសរសេរប្រាប់ទៅបន្ថែម ៖

«ខ្ញុំចង់អានឯកសារសំណុំរឿងឃាតកម្មជាងបញ្ចូលភ្លេងទូរសព្ទឈ្មោះនៃ ត្រូវហើយ ឈ្មោះណិច នៅស្ទឹងហាវកាលពី១០ឆ្នាំមុន! »

«z22?»

«ឯងដឹងរឿងហ្នឹងដែរពៅ?»

Royសួរហើយឆ្ងល់ចំហមាត់។

ប៉ូលិសឈ្មោះពៅតបវិញបន្ទាន់៖

«ពូខ្ញុំកាលមុននៅក្រុងព្រះសីហនុ! គាត់ដឹងរឿងហ្នឹងច្បាស់! មេធាវីអាមេរិកប្រចណ្ឌប្រពន្ធតាមស៊ើបនៅស្ទឹងហាវក៏ពាក់ព័ន្ធនិងfolderគីមីពុលមួយ!»

Roy គោះតុត្រេកអរ៖

«ឯងគ្រាន់បើ! រឿងហ្នឹងច្បាស់ហើយ! ខ្ញុំនៅអង់គ្លេសមិនដឹងរឿងអីទាំងអស់! អូខេៗ ខ្ញុំចង់បានឯកសារលំអិត ខ្ញុំចង់អានវាខ្លួនឯង!»

«វាទំនងជាបញ្ជូនមកភ្នំពេញយូរហើយទាន!»

«អូខេរកមកឱ្យខ្ញុំកាន់តែឆាប់កាន់តែល្អ!»

«បាទទាន!»

គេនៅស្ងៀមម្នាក់ឯងបញ្ឈប់ការឆាត។

ដៃគេចាក់ទឹកក្តៅពីក្នុងប៉ាន់មកកាន់យកកម្តៅដៃតែមិនបានក្រេបទេ។ យសរបស់គេ នៅឬទៅ អាស្រ័យលើក្តារអុកចុងក្រោយនេះ ម៉្លោះហើយគេបោះចោលរឿងគ្រប់យ៉ាងទៅម្ខាង ហើយផ្តោតតែលើការងារចំពោះមុខ។

Royរអ៊ូម្នាក់ឯង៖

«ឯងប្រើគ្រួសារសេតវិទូពាក់ព័ន្ធក្នុងចរន្តលុយតាហោរា ចង់ប្រាប់យើងអំពីអីអាចង្រៃ!»

ទូរស័ព្ទគេរោទ៍។ Royសម្លឹងនាឡិកាម៉ោងពីរភ្លឺឥឡូវហើយ។ ដំណឹងមិនល្អច្បាស់ណាស់ បើគិតតាមវដ្តនៃអំពើឃាតកម្ម ដំណាក់កាលនេះជាដំណាក់កាលដែលសាក្សីសំខាន់ណាម្នាក់ត្រូវគេសំឡេះ។

ចិត្តគេនឹកព្រួចដល់មហាវីន។ អ្នកមានកន្ទាត់នោះច្បាស់ណាស់មិនមែនជាមេខ្លោងទេ ប៉ុន្តែជាសាក្សីពាក់ព័ន្ធដ៏សំខាន់មួយ។

គេធ្លាប់ត្រូវសំឡេះសឹងគ្រោះរក្សាជីវិតមិនគង់ទៅហើយ ក៏គេនៅតែរឹងត្អឹងមិនព្រមហែក
ត្រដាងការពិតជាច្រើនទៀតប្រាប់មកប៉ូលិសសោះ តើមកពីហេតុអ្វី?

ដៃស្នងការក្មេងចុចទទួល៖

«អាឡូ!»

សំឡេងកូនចៅជំនិតដែលគេស្គាល់ច្បាស់និយាយប្រាប់ខ្សឹបៗ៖

«មេ! របាយការណ៍គ្រោះថ្នាក់ចរាចរណ៍ប្រចាំថ្ងៃរាយការណ៍គ្រួសារតាពាងស្លាប់លើផ្លូវចេញពីស្រុកកំណើតមកភ្នំពេញវិញ!»

Royហើបគូទពីកៅអី។

ភ្នែកនាយចេញកម្តៅ ហើយដៃចាប់ផ្តើមញ័រ។ សំឡេងអ្នករាយការណ៍នៅតែលាន់មកបន្ត៖

«អ្នកបើកឡាន និងតាពាង ប្រពន្ធគាត់ កូនប្រសា កូនបង្កើត គ្មានសល់ម្នាក់ទេទាន!»

Royខាំមាត់មុនពេលសួរខ្លី៖

«សពនៅឯណា?»

គេឃើញឡានទំនើបរបស់ស្នងការRoyចេញរឹងទៅខេត្តទាំងយប់។

នៅលើឡានដែលរួមដំណើរដោយប៉ូលិសបីនាក់ផ្សេងទៀត គេខលទៅអមរាជា។

«បងសុំទោសទូរស័ព្ទថ្មើរណេះតែបងមានរឿងបន្ទាន់! ហេតុអីខលប៉ាអូនចូល?»

អមរាជាឆ្លើយតបហាក់បីដូចជានាងក្រោកពីគេងយូរមកហើយដូចគ្នា៖

«ប៉ាចេញពីផ្ទះទៅមុននេះបន្តិច ជាមួយប៉ូលិសច្រើនដែរ! គាត់អត់បានប្រាប់អីផងតែមានកូនចៅគាត់ម្នាក់និយាយនឹងពូហឿនថា ថ្នាក់លើហៅប្រជុំបន្ទាន់!»

គេលានាងទាំងកើតក្តីសង្ស័យ។

«គេប្រជុំអីនៅក្រសួង ហេតុអីយើងមិនដឹង? ហេតុអីប្រជុំទាំងថ្មើរណេះ»

គ្មានកូនចៅណាម្នាក់អាចមានចម្លើយត្រឡប់មកវិញឱ្យនាយឡើយ។ ស្នងការក្មេងកាន់តែ

ល្អិតល្អៃ។ គេនិយាយប្រាប់ខ្លួនឯងស្ងាត់ៗ ៖ «គេប្រជុំសំខាន់ដល់ថ្នាក់បិទទូរស័ព្ទ គេប្រាប់ពូសាម៉ុន ពីការដកតំណែងយើងពិតណាស់!»

«ហេតុអីមេចាំបាច់ទៅខេត្តពិនិត្យទីកើតហេតុខ្លួនឯងទាន?»

កូនចៅម្នាក់អង្គុយនៅបាំងខាងមុខក្បែរសូហ្វ៊ូសួរមកRoy ធ្វើឱ្យគេនឹកឃើញសារឡើងវិញនូវដំណាក់កាលសំខាន់នៃបេសកកម្មមួយនេះ។

«អាRoy! មិនថាឯងតោងកៅអីស្ទងការជាប់ឬអត់? បើឯងជាកូនប្រុសត្រូវរកមុខអានាក់នៅពីក្រោយល្ខោនវែងអន្លាយនេះឱ្យខាងតែបាន!»

គិតហើយ គេមិនឆ្លើយសំណួរកូនចៅបែរជាដាក់បញ្ជា៖

«បងផល! បងឯងទាក់ទងគ្នាយើងនៅភ្នំពេញរកកម្លាំងចំណាប់ៗ ឱ្យតាមឃ្លាំមនុស្សបីនាក់ឱ្យខ្ញុំ ម្ភៃបួនម៉ោង លើម្ភៃបួនម៉ោង!»

ពេលដែលដៃកូនចៅនាំគ្នាកត់បទបញ្ជាញាប់ស្មេរ គេនិយាយបន្ថែម៖

«ម្នាក់ឈ្មោះមហាវីន ! ជនល្មើសឈ្មោះដេវីតដែលកំពុងរង់ចាំឡើងតុលាការការពារឱ្យតឹងតែង!»

«ចុះម្នាក់ទៀតមេ?»

គេនៅស្ងៀមធ្វើមុខមាំ លើកម្រាមដៃមកខាំតិចៗមុនពេលនិយាយបង្ហើយ៖

«ជំនួយការរបស់Lorenzoឈ្មោះវឌ្ឍនៈ»

កូនចៅទាំងបីនៅស្ងៀមក្នុងបរិយាកាសក្រៀមស្រពោន។ គេយល់គ្រប់គ្នាថា ចៅហ្វាយម្នាក់នេះ ទឹកដល់ច្រមុះទៅហើយ នៅតែមាំទាំគិតរកក្រឡាស្ដួចមេខ្លោងឱ្យខាងតែបានព្រោះមនុស្សទាំងបីដែលគេបញ្ជាឱ្យឃ្លាំ សុទ្ធតែមានទំនាក់ទំនងសំខាន់នឹងសំណុំរឿង ដ៏ព័ទ្ធពេនចាក់ស្រេះមួយនេះ។

ភាគទី៤២

វគ្គ ជនសង្ស័យ

នៅក្នុងច្រកតូចងងឹតស្លុបចិត្រាឈប់ម៉ូតូហើយរេរំពៃពិនិត្យឆ្វេងស្តាំ។ ពន្លឺស្រាលស្រទន់នៃអំពូលមិនគ្រប់កម្លាំងភ្លើង ចាំងជះមកលើគែមផ្លូវ នៅចម្ងាយប្រមាណជា៣០ម៉ែត្រស្ទង់ៗ ពីមុខនាយ បង្ហាញហាក់មានអ្នកណាម្នាក់ពួនលឹបលនៅទីនោះ។

គេជិះយឺតៗ ចូលទៅកាន់ប្រភពពន្លឺ។ មនុស្សទាបកន្ទើម្នាក់បង្ហាញស្រមោល។

មិនយូរប៉ុន្មាន នាយសក្តិបួនទៅដល់ក្បែរគេនោះហើយខ្សឹបខ្សៀវសួរភ្លាម៖

«ឯណាអាមាន!»

ឈុនរាជគឺជាអ្នកដែលកំពុងឈររង់ចាំគេនោះហើយ។ បើកុំតែប្រធាននិស្សិតជាអ្នកផ្តល់ដំណឹងឱ្យ គេមកជួបជាមួយឯកមាន ពេលនេះគេម៉េចនឹងប្តូរទិសដៅ ដែលកំពុងតែមានដំណើរត្រូវទៅរកពូបង្កើតរបស់ខ្លួនហើយមកកាន់ តំបន់ផ្ទះសំណាក់រខេករខាកនេះ។

ចិត្រាមិនដឹងថា តើឈុនរាជអាចរកឯកមានឃើញដោយវិធីណានោះទេ តែគេរឹតតែឆ្ងល់ដែលថា ហេតុអី ឈុនរាជតក់ក្រហល់ឱ្យខ្លួនមកជួបឯកមាននៅកន្លែងនេះ ។

«ឡើងទៅលើតោះ! »

មេកាងសាលានិយាយម៉ាត់ៗហាក់ប្រុងប្រយ័ត្ននិងប្រញិបប្រញាប់ផងធ្វើឱ្យសក្តិបួនរឹតតែកើតចិត្តឆ្ងល់។

«ហើយចុះអ្នកនាងផានូ?»

គេពោលសួរព្រោះឃើញសភាពកន្លែងនេះមិនសមថាឈុនរាជយកស្រីអភិជនដូចនាងមកស្នាក់នៅ។

ឈុនរាជខ្សឹប៖

«នៅជាមួយមិត្តភក្តិរបស់ឯង!»

ចិត្រាកាន់តែឆ្ងល់ ឯជើងក៏ចេះតែដើរតាមពីជាន់មួយដល់ជាន់មួយ ពីអគារមួយដល់អគារមួយ។ គូកំណាន់នានាមានតាំងពីយុវវ័យរហូតដល់សក់ពីរពណ៌ បណ្ដើរគ្នាចេញចូលផ្ទះសំណាក់នេះជាមួយកាយវិការអាសអាភាសនិងស្រវឹងឆួល។

«ម៉េចមិនឱ្យទៅផ្ទះឧត្ដមសេនីយ៍!»

គេសួរទាំងមិនអស់ចិត្ត។ តែឈុនរាជហាក់គ្មានកង្វល់អ្វីក្នុងការឆ្លើយប្រាប់សោះ គេនិយាយខ្លីៗ៖

«ឯកមាននោះឱ្យខ្ញុំធ្វើអ៊ីចឹង!»

«អាមានរកឃើញរឿងស្អីវាទៀតហើយ? វានឹកឃើញម៉េចនាំកូនស្រីគេមកកន្លែងនេះ?»

ចិត្រានឹកបែបនេះស្ងាត់ៗក្នុងចិត្តតែម្នាក់ឯង រហូតដល់ឃើញឈុនរាជឈប់នៅមុខបន្ទប់ចុងគេមួយហើយគោះទ្វារបីប៉ូក។

«អាថ៌កំបាំងម្ល៉េះទេពួកអស់នេះ?»

គេគិតទាំងសៅហ្មងឈឺក្បាល។ ករណីសំខាន់មួយទៀតគឺចង់ឃើញថាអ្នកនាងផានូរបស់ស្រីតូចអមរាដានៅសុខសាន្តមិនបាត់មួយសរសៃសក់។

ទ្វាររបើកចូលខាងក្នុង អ្វីដែលចិត្រាឃើញមុនគេគឺស្រីតូចផានូស្គមស្លក់អង្គុយត្របោមក្នុងឈុតអ្នកស្រុកមើលមិនចង់ស្គាល់។ នាងហាក់អរណាស់ពេលឃើញគេ ប៉ុន្តែ ឯកមានវិញគេអង្គុយបែរខ្នងរវល់ញាប់ដៃជាមួយកុំព្យូទ័រមួយ។ សូម្បីតែចិត្រាមកដល់ហើយ គេគួរណាស់តែងាកមក ប៉ុន្តែអ្វីម្យ៉ាងក្នុងកុំព្យូទ័រហាក់បីដូចជាសំខាន់ជាងអ្វីគ្រប់យ៉ាងចំពោះឯកមាន។

«ឯងនៅរស់ទេ?»

ចិត្រាសួរព្រោះខឹងដែលគ្រប់គ្នាបារម្ភពីគេមួយនគរ គេបែរជាមកកាន់ទីនេះជាមួយឈុនរាជមិនខ្វីទាក់ទងមកខ្លួនដែលជាមិត្តសម្លាញ់។

«អាចិត្រ អញរកឃើញស្អីមួយប៉ះសក់!»

គេនិយាយហើយបន្តការងារតទៅទៀត មិនងាកមកដដែលធ្វើឱ្យចិត្រាបែរមកយឹតៗរកផានូ។

អ្នកនាងម្នាក់នេះ នៅមានដានទឹកភ្នែកស្ងួតជាប់ថ្ពាល់នៅឡើយ មិនដឹងទេថាតើជាងម្ភៃម៉ោង

មកនេះស្រីស្អាតដែលតែងតែរួសរាយបានឆ្លងកាត់ហេតុការណ៍អ្វីខ្លះ បានជាតរុណីបន្ទាបខ្លួន ព្រមមកសំងំនៅទីនេះជាមួយឯកមាន។

គេអោនទៅជិតហើយចាប់ផ្ដើមសួរខ្សឹបខ្សៀវ៖

«អ្នកនាងផានូ រឿងហេតុយ៉ាងម៉េចខ្លះ?»

នាងចាប់ផ្ដើមរលីងរលោងហើយស្លេកស្លាំងលើសដើម។ ចិត្តអង្គរក្សអាណោចអាធ័មសម្លឹង ស្រីស្អាតដែលស្រពោនដូចបុប្ផាចាកទង។

នាងគ្រវីក្បាល យឺតៗមុននឹងឆ្លើយចេញអណ្ដឺតអណ្ដក៖

«ខ្ញុំគិតអីមិនយល់ទេចិត្រា! ខ្ញុំចង់ឱ្យបងឯងយកខ្ញុំទៅផ្ទះវិញ!»

គេងាកទៅក្រោយខ្នង ឈុនរាជឈរទីទើរនៅក្បែរទ្វារ។ ទឹកមុខអ្នកកាងសាលាគឺពេញដោយ ការអាណិតអាសូរលើសិស្សប្អូនម្នាក់នេះរួចទៅហើយ គេគ្មានរឿងអ្វីត្រូវបង្អាក់មិនឱ្យផានូ ទៅផ្ទះវិញតាមចិត្តចង់បានរបស់នាងនោះទេ។

នាយបែរទៅរកក្លើឯកមានហើយសម្លុតសួរ៖

«ចម្ងាយហ្នឹងសោះ អ្ហែងមិននាំអ្នកនាងផានូ ត្រឡប់ទៅផ្ទះសិន?»

ឯកមាននៅសម្លឹងកុំព្យូទ័រស្ទើរជ្រុះភ្នែកធ្វើឱ្យចិត្រាកាន់តែស្មុគចិត្ត។ គេច្រត់ចង្កេះរបៀបខឹង ធ្វើឱ្យឈុនរាជស្ទុះមកជិតហើយខ្សឹបខ្សៀវ៖

«សក្តិប្អូនឯកមាន សង្ស័យឧត្តមសេនីយ៍ឯក ឱិត សាម៉ុន នៅពីក្រោយការចាប់ស្រីៗ»

ដូចត្រូវទឹកជះចំកណ្ដាលមុខ គេបែរមករកឈុនរាជវិញមួយរំពេចទាំងដឹងហើយថាអ្នកកាង សាលាមានថ្វើមពាសមេឃក៏មិនហ៊ានប្រឌិតសម្ដីនេះឡើងដែរ។

គេងាកទៅមិត្តជាhacker បម្រុងកេះសួរតែឯកមានរាដៃឃាត់គេទាំងនិយាយខ្លី៖

«ទុកពេលអញ៥នាទី!»

កូដជាច្រើនលោតញាប់ស្អេកក្នុងScreenរបស់Hackerធ្វើឱ្យចិត្រាជ្រួលច្របល់ឈរទ្រឹង។ គេមិនដឹងគិតពីណាទៅណាហើយសួរសំណួរអ្វីឱ្យចំដៃរនៅពេលនេះ។

សំឡេងផានូលាន់មកពីក្រោយខ្នង៖

«ដំបូង ពួកខ្ញុំរត់ដល់ផ្លូវលំចេញពីភូមិតូចមួយ មានម៉ូតូមក៥គ្រឿងខ្ញុំស្មានថាពួកប៉ូលិសតាមមកចាប់ពួកយើង ដឹងអីពួកគេមកតាមរកពួកខ្ញុំសោះ! ពេលនោះនៅងងឹត មេឃមិនទាន់ភ្លឺ ពួកគេឱ្យយើងផ្លាស់ខោអាវពួនក្នុងផ្ទះអ្នកស្រុកមួយ បងឯកមានរកទាក់ទងមកបងឯងតែគាត់ខលមិនចូល ខ្ញុំមិនដឹងធ្វើម៉េចមានតែខលពូសាម៉ុន! គាត់ប្រាប់ថា នឹងឱ្យប៉ូលិសមកទទួល តែបងឯកមានថាមិនទុកចិត្តប៉ូលិសទេក៏មិនព្រមទៅ ចង់ជួបតែបងឯង ភ្លាមនោះក៏មានមនុស្សមកសួររកពួកខ្ញុំ! កុំតែកម្លាំងខាងណោះខ្លាំងជាងកុំអីពួកនោះមកនាំពួកខ្ញុំបង្ខំចេញទាំងបងឈុនរាជមិនទាន់មកដល់ផង! »

«ហើយមានទាក់ទងអីនឹងឈុនរាជ?»

ឈុនរាជនិយាយមួយៗ៖

«មកដល់ផ្ទះ យើងដេកមិនលក់បក់មិនល្ហើយ ក៏ចាប់ផ្តើមស្វែងរកបណ្តាញឱ្យជួយជិះរុករកមើលគេទាំងពីរនៅបណ្តាតំបន់ដែលយើងសង្ស័យ! »

ចិត្រាទើបនឹងយល់ថាតាមពិត៥នាក់ដែលជិះម៉ូតូទៅជួយឯកមាននិងផានូជាមនុស្សត្រូវឈុនរាជពឹងមកសោះ គេអស់ចម្ងល់ថាហេតុអ្វីស្រីប្រុសទាំងពីរចេញមកបាន ប៉ុន្តែចម្ងល់ដែលនៅសល់គឺថា ហេតុអីក៏ឱតសាម៉ុនដឹងដំណឹងឯកមាន និងផានូហើយហើយមិនព្រមនិយាយ?

គេគិតចុះឡើងដោយដោយច្រាស់ច្រាល់។ រំពេចនោះឯកមានងាកមកនិយាយផ្ទួង៖

«ចប់ហើយ! អាចិត្រ! មកមើល៍!»

ចិត្រាមិនដែលចេះមើលកូដទេទោះបីយ៉ាងណាគេនៅតែស្ទុះទៅ។ ឯកមាន ចង្អុលពន្យល់ហើយនិយាយ៖

«អាលេខមួយសំណុំនេះ វាបានចូលទៅផ្តាច់ទំនាក់ទំនងរវាងទូរសព្ទអញ ទូរសព្ទអ្នកនាងផានូ និងទូរសព្ទរបស់ឈុនរាជ! លេខនេះគេប្រើវាជាមួយSystemដែលបង្កប់ក្នុងសេវាចេញពីFolderមួយ!ប៉ូលិសពីរបីនាក់យកវាមកឱ្យពួកអញពេលចេញឡានទៅសមោសរពណ៌ព្រះចន្ទ! ឯងមើលម្តងទៀត អាលេខមួយសំណុំដដែលនេះ មានការទាក់ទងចូលផ្ទះឱិតសាម៉ុន៥លើក ហើយទាក់ទងជាមួយលេខរបស់Lorenzo លេខក្រហមពីនេះសង្ស័យជាកូដប្រើរបស់ពួកhackerបរទេសដែលកម្រិតវាខ្ពស់មិនអាចតាមដានដឹង! ប៉ុន្តែចុងក្រោយយើងអាចដឹងរឿងពីរដែលមានប្រភពតែមួយគឺ ឱិតសាម៉ុន ពាក់ព័ន្ធជាមួយលេខhackមួយនេះហើយប៉ូលិសដែលគាត់ចាត់ឱ្យមកតាមការពារពួកអញតាមពិតគឺឱ្យមកធ្វើកពួកអញ!»

ហេតុអ្វីឱិត សាម៉ុនថៃមទាំងមានទំនាក់ទំនងនិងសំណុំកូដនោះដែរ ហើយចុងក្រោយគាត់ថៃមទាំងមិនព្រមឱ្យព័ត៌មានខ្លួនអំពីរឿងឯកមាន។ «គាត់ថៃមទាំងឃាត់ស្នងការRoyមិនឱ្យនិយាយរឿងផានូបាត់ដានប្រាប់មហាជនទៀត?» រឿងហេតុកាន់តែសាំញ៉ាំ?

គេបែរមុខយឺតៗចេញពីឯកមានហើយមើលមកប្រធាននិស្សិតដែលឈរចំហមាត់។ ទោះចិត្រាមិនទាន់មានប្រតិកម្មអ្វីក៏ឈុនរាជប្រញាប់រាដៃបដិសេធភ្លាមៗ៖

«កុំរាប់បងបញ្ចូល! បងទុកថាខ្លួនឯងមិនដឹងរឿងអីទាំងអស់! បងមានភារកិច្ចសំខាន់តែមួយគត់គឺការពារកិត្តិយសអ្នកកាងសាលាឱ្យបានដល់ទីបញ្ចប់ នាំសិស្សប្អូនផានូទៅដល់ផ្ទះប្រកបដោយសុវត្ថិភាព!»

ឯកមានបន្តការងាររបស់គេចំណែកឈុនរាជងាកទៅនិយាយជាមួយផានូ៖

«តោះ! ទៅផ្ទះជាមួយបង!»

«ក្រៅពីខ្ញុំ គ្មានអ្នកណានាំគេទៅបានទេ!»

ឯកមាននិយាយមិនបែរខ្នង ធ្វើឱ្យចិត្រាសឹងបះសក់ច្រូង។ Hackerក្រីក្រហ៊ានប្តូរមកហៅស្រីស្រស់ត្រកូលហង្សថា«គេ»របៀបណានៀក?

ផានូហាក់នៅទីទើរមិនហ៊ានដើរចោលឯកមានដូចគ្នា ធ្វើឱ្យចិត្រាវឹងរឹតតែស្ញាត់មាត់ឡើង ព្រោះមិនដឹងឡើយថា រយៈពេលរត់លូនមកនេះ ស្រីប្រុសទាំងទ្វេបានឆ្លងកាត់អ្វីខ្លះរហូតដល់ស្រីស្អាត ត្រូវបាក់ស្បាតហើយយល់មុខឯកមានដល់ថ្នាក់នេះ។

«ឯងទៅជាមួយបងដែរអត់ផានូ?»

បងឈុនរាជនិយាយមួយៗ ហាក់ចង់ឈ្នះចិត្តឯកមាន ចំណែកផានូរឹតតែស្ងាក់ស្ទើរសម្លឹងបុរសទាំងទ្វេ។

ឯកមាននៅស្ងៀមដោយមុខស្មើ គេបែរខ្នងរង់ចាំស្ដាប់សម្ដីនាងដូចគ្នា។ ផានូដកដង្ហើមធំមិនព្រមមានចម្លើយ ធ្វើឱ្យឈុនរាជនិយាយបន្ថែម៖

«បើបងគ្មានបណ្ដាញច្រើនជួលគេទៅរុករកឯង ឯងស្មានថាបានមកអង្គុយស្រណុកអ៊ីចឹងហ្អី?»

«ឯងគិតហ្អីថាចម្ងាយនេះឯងអាចជូនគេទៅដល់ផ្ទះ?»

ឯកមានសួរមុខស្មើក្នុងកិរិយាមាំធ្វើឱ្យឈុនរាជចង់ភ័យដកយកទឹកដោះគោក្នុងហោប៉ៅ មកបឺតទាំងត្អូញ៖

«កុំសម្លុតយើងវ៉ី! យើងជាមនុស្សខ្វះជាតិស្ករ បើយើងសន្លប់ម្នាក់ទៀត ឯងពិបាកសែងមិនខានអាប្អូនសក្ដិបួន! »

ឯកមានឆ្លើយទាំងមួម៉ៅ ៖

«មនុស្សឱត សាម៉ុនគ្រោះថ្នាក់ណាស់! យើងដឹងរឿងគេច្រើន គេមិនឱ្យយើងសុខទេ! គេអាចនឹងបំបាត់ដាន ស្អីក៏គេហ៊ានធ្វើដែរ! មនុស្សគេនេះ! ឯងគិតមើលស្រីៗបាត់ខ្លួនសុទ្ធតែកូនអ្នកមាន កូនស្រីគេឆ្នាំរោងដែរម្ដេចមិនអី? ហេតុអីយើងចេញមកជាមួយគ្នាត្រូវជាប់ជុចកណ្ដាលផ្លូវបាន បើមិនមែនមេប៉ូលិសធ្វើ អ្នកណាមានដៃធំដល់ម្លឹង? ពេលនេះយើងលំបាកណាស់

ទម្រាំពួនសុខហើយនាំអាចិត្រមករកមធ្យោបាយបើពីរនាក់ឯងចេញទៅត្រូវគេនាំទៅបាត់ ឱ្យយើងធ្វើម៉េចរកមុខតានោះបាន?»

ឈុនរាជឈប់បឺតភេសជ្ជៈឈរទ្រឹង។

ចំណែកចិត្រានិយាយកាត់៖

«យើងមិនទាន់មានអ្វីសំអាងថាគ្រប់យ៉ាងដែលឯងនិយាយជាការពិត១០០ភាគរយទេឯកមាន?!ចំណែកអ្នកនាងផានូជាមនុស្សស្រី នាងត្រូវតែទៅផ្ទះ! មិនអ៊ីចឹងទេអ្នកផ្ទះលែងអត់ធ្មត់ហើយ!»

ឯកមានហាក់មានសេណារីយោអ្វីចង់ធ្វើ បានជាសម្លឹញចង់ជួបចិត្រា។

ផានូយល់ពីករណីនេះ ទើបនាងសម្រេចចិត្តហាមាត់និយាយកាត់សេចក្តី៖

«ខ្ញុំនៅបន្តិចទៀតក៏មិនអីដែរ!  បើថានេះចាំខ្ញុំខលទៅប្រាប់អ្នកផ្ទះមួយម៉ាត់កុំឱ្យគាត់បារម្ភ!»

ឯកមានងាកមកឃាត់ដោយសំឡេងស្រទន់៖

«មិនបានទេ!»

ផានូនិយាយពន្យល់វិញស្រាលៗភ្លាម៖

«ខ្ញុំនឹងប្រាប់អ្នកផ្ទះថាមិនឱ្យពូសាម៉ុនដឹងដាច់ខាត!»

ឯកមាននៅតែគ្រវីក្បាលនិយាយ៖

«យើងម៉េចនឹងដឹងថាឱិត សាម៉ុនបានលបស្តាប់ទូរសព្ទអ្នកណាខ្លះ? ហើយមនុស្សរបស់គេនៅគ្រប់កន្លែង យើងមិនបានសុខទេ!»

ម្នាក់ៗនៅស្ងាត់ស្ងៀម ចំណែកឯកមានថយកៅអីមកក្បែរផានូហើយចាប់កាន់បាតដៃនាងទាំងសងខាង។ ចិត្រាដឹងថាប្រុសស្រីទាំងទ្វេបានប្រគល់បេះដូងឱ្យគ្នារួចស្រេចទៅហើយ។ គេងាកមុខចេញទាំងអៀនប្រៀន។ ចិត្តមួយនឹកទៅដល់អមរាជាម្ចាស់ចិត្តហើយចុងក្រោយនឹកទៅដល់ ឧត្តមសេនីយ៍ឱិត សាម៉ុន។

បុរសចំណាស់ដែលខ្លួនគោរពម្នាក់នោះមែនទេនៅពីក្រោយរឿងរញ៉េរញ៉ៃអស់ទាំងនេះ?

«ចុះបង! ពួកឯងឱ្យបងមកឈរធ្វើទីងមោងអីនៅកន្លែងនេះ?»

ឈុនរាជសួរឡើង ធ្វើឱ្យគ្រប់គ្នាងាកមករកគេ។

ឯកមានសួរវិញភ្លែត៖

«ប្រធាននិស្សិតស្អីកំសាក ដឹងរឿងធ្វើមិនដឹង! មុនពេលយើងបែកគ្នាខ្ញុំប្រាប់ឯងថាម៉េច? ខ្ញុំថាប៉ូលិសនៅពីក្រោយរឿងអាថ៌កំបាំងធ្វើបាបពួកយើង! ម៉េចឯងមិនប្ដឹងប៉ូលិស? »

ឈុនរាជនិយាយវិញទាំងស្ទាក់ស្ទើរ៖

«យើងប្រាប់ពូឱិត សាម៉ុនរួចហើយ! តែគាត់ថាពួកគេបន្លំ!»

«ចុះរហូតដល់ពេលនេះប៉ូលិសរកឃើញមុខសញ្ញាបន្លំអស់ហ្នឹងដែរអត់?»

ឯកមានដេញសួរ។

ចិត្រឆ្លើយតបមួយៗទាំងរភ្នែកគិតចុះឡើង៖

«នៅទេ!»

ឯកមាននិយាយបន្ថែម៖

«យើងត្រូវការជួបស្រីៗទាំងអស់ដែលឈុនរាជឯងជួយដើម្បីសួរនាំគេរបៀបដែលគេត្រូវចាប់ទៅ!ហើយយើងនឹងដឹងការពិតមិនខាន»

ចិត្រានិយាយកាត់៖

«អត់ប្រយោជន៍ទេ! សូម្បីមេប៉ូលិសធំៗក៏ខាងគ្រួសារជនរងគ្រោះមិនទាន់ព្រមសហការផ្ដល់ចម្លើយផង!  គេយកលេសថាកូនស្រីទាំងនោះនៅភ័យខ្លាចនៅភ្លេចភ្លាំង! »

ឯកមាននិយាយបញ្ច្រាសវិញ៖

«ហ្នឹងហើយឃើញអត់! ពួកនាងក៏ប្រហែលជាមានតម្រុយដឹងថា ពួកប៉ូលិសនៅពីក្រោយរឿងនេះបានជាមិនព្រមជួបសហការ! ថាអីខុស!»

ចិត្រាជ្រួញចិញ្ចើមគិត។ ដល់វេនផានូនិយាយនឹងឈុនរាជម្តង៖

«សិស្សច្បង! លើកនេះខ្ញុំព្រមស្តាប់តាមសម្តីឯកមាន ព្រោះលើកមុនខ្ញុំមិនស្តាប់គេ យក Flashមួយនោះចូលមកក្នុងឡានធ្វើឱ្យយើងត្រូវចូលស៊ងគេទាំងអស់! លើកនេះខ្ញុំចង់ធ្វើតាមគេឱ្យចប់ចុងចប់ដើម!»

«ប្អូនចង់នៅកន្លែងនេះយូរប៉ុនណា?»

ឈុនរាជសួរដោយអាការៈមិនស្រណុកចិត្ត។ គ្រប់គ្នាងាកទៅរកឯកមានរង់ចាំចម្លើយពីគេ។

Hackerដកដង្ហើមវែងៗហើយនិយាយ៖

«ចិត្រា! ឯងជាអ្នកចេញទៅរកមធ្យោបាយតាមដានវេកមុខតាប៉ិឧត្តមសេនីយ៍ យើងនៅទីនេះរង់ចាំដំណឹងមានអីយើងធ្វើបានប្រាប់មក យើងជួយឯងពីកន្លែងនេះទៅ ចំណែកយើងដើរចោលផានូមិនបានព្រោះគេត្រូវមានសុវត្ថិភាព!»

«ឯងគិតថានៅនេះមានសុវត្ថិភាព?»

«បងឈុនរាជនៅទីនេះទាំងមូល!»

ឯកមាននិយាយឌឺធ្វើឱ្យ ឈុនរាជបើកភ្នែកធំៗ ៖

«ឯងចង់ឱ្យយើងនៅទីនេះដែរ?»

ចិត្រាយល់ហើយពីបំណងឯកមាន។ ចិត្តគេស្រលាញ់ទេពធីតាតែគេនៅតែចង់រក្សាភាពស្អាតស្អំឱ្យនាងបានជាទុកបងឈុនរាជនៅជាមួយ។ ទោះបីយ៉ាងណាគេនៅជុំគ្នាបីនាក់ ចិត្រាក៏ហាក់ទុកចិត្តជាងមុន។ បីនាក់នេះ បើមិនរាប់ថាខ្លាំងក៏មិនអាចចាត់ថាខ្សោយដែរ។ គេឆ្លងកាត់ឧបសគ្គមកមិនតិចទេ ដូច្នេះគេអាចគ្រប់គ្រងស្ថានភាពបានពិតណាស់។

ឯកមានមិនឆ្លើយនឹងសំណួររបស់ឈុនរាជទេ ព្រោះគេយល់ថាមិនចាំបាច់។ មនុស្សដូចមេកាងសាលាចម្លែកម្នាក់នេះ ស្គាល់ច្បាស់ទើបដឹងថាសន្តានចិត្តពេញដោយគុណធម៌និងការទទួលខុសត្រូវ។ គេធ្លាប់ផ្សងគ្រោះថ្នាក់ឱ្យសិស្សប្អូនរត់យករួចខ្លួន កុំថាឡើយពេលនេះមកឱ្យនាងនៅសំងំតែពីរនាក់ឯកមាន ហើយគេវិលទៅវិញដេកលក់។

Hacker ឆ្លៀតនិយាយចំអន់៖

«តែសុំទោស! យើងប្រហែលជាមិនអាចកុម្ម៉ង់ ទឹកដោះគោមកឱ្យឯងបានទេ ព្រោះឌិត សាម៉ុនដែលបាត់ឯង គេអាចនឹងតាមដាន តាមរយៈអ្នកទិញទឹកដោះគោបាន!»

ថាចប់គេសើចក្អាកក្អាយ។

ចិត្រាថយទៅរកមាត់ទ្វារទាំងតឹងតែងក្នុងចិត្ត។ រហូតដល់ពេលនេះឯកមាននៅតែមិនទាន់ឮមិត្តរបស់ខ្លួន និយាយអ្វីវាយតម្លៃលើការសន្និដ្ឋានរបស់គេពាក់ព័ន្ធនិងឧត្តមសេនីយ៍ឌិត សាម៉ុនម្នាក់នោះសូម្បីមួយម៉ាត់ណានៅឡើយ ដូច្នេះហើយគេប្តូរទឹកមុខ ក្រោកទៅក្បែរចិត្រា ហើយកេះនិយាយ៖

«បើឯងគិតមិនចេញឈឺក្បាលពេក! ហៅពូឯងជួយគិតទៅ! គាត់គ្មានរឿងអីថាដោះមិនចេញទេ កាលីបត្រឹមឌិត សាម៉ុន!»

ចិត្រានឹកឃើញឡើងវិញភ្លាមដល់រឿងដែលខ្លួនត្រូវទៅជួបលោកមា។ ព្រឹកមិញគាត់ក៏បានខលមកហើយថែមទាំងហាមប្រាមមិនឱ្យនិយាយរឿងទាំងអស់ប្រាប់អ្នកណា។ បើកុំតែនៅទីនេះ មានវត្តមានឈុនរាជនិងផាន្ទ កុំអីគេមុខតែពិភាក្សានិងឯកមានហើយថាមកដល់ពេលនេះ SMS របស់ពូគេក៏បានសរសេរដែរថា «អ្នកណាម្នាក់កំពុងធ្វើបាបLorenzo ហើយគាត់គិតថាអាចជាមនុស្សក្នុងចំណោមពួកប៉ូលិស!»។ ចំណុចនេះគឺវាដូចគ្នានឹងអ្វីដែលឯកមានសន្និដ្ឋាន។

គេងើបមុខសួរមិត្តខ្សឹបៗ៖

«រឿងប្រទាក់ក្រឡាគ្នាវែងឆ្ងាយវិលវល់បែកផ្សេង!  ហេតុអីជាឌិត សាម៉ុន? គេធ្វើរឿងច្រើនអ៊ីចឹងដើម្បីអ្វី?»

ឯកមានក្រពាត់ដៃឆ្លើយតបធ្វើវាហី៖

«បើអញរកឃើញបំណងវា អញបកអាក្រាតវាបាត់ហើយ! អញត្រូវការលុយ៥០០លានសងបំណុលគេ!»

ចិត្រាហួសចិត្តនិយាយតបវិញផ្ទួង៖

«ស្រីៗរំដោះមកហើយ បើបាន គួរតែបងឈុនរាជ ជាអ្នកបាន!»

ឃើញបងឈុនរាជស្តាប់ហើយធ្វើក្រអឺតហុចទឹកភេសជ្ជៈដែលទើបនឹងទិញពីក្រៅមួយស្បោងធំនោះ មកឱ្យទៅផាន្ទ ឯកមាននិយាយដៀមដាម៖

«ឆាកធំមិនទាន់ដល់! មេខ្លោងមិនទាន់ពាក់ខ្មោះ! អ្នកដែលត្រូវទទួល៥០០លានរៀល មិនទាន់កំណត់បានថាអ្នកណាទេវ៉ី!»

ភាគទី៤៣

## វគ្គ គាស់កកាយអាថ៌កំបាំងថ្មី

ទើបតែនឹកឃើញថា២ឆ្នាំហើយ គេមិនដែលមកលេងផ្ទះលោកមាទាល់តែសោះ។ ម្យ៉ាងខ្លួនមានភារកិច្ចមមាញឹក ម្យ៉ាងលោកពូចូលចិត្តស្ងប់ស្ងាត់មិនចង់ជជែកការកិច្ចនយោបាយសន្តិសុខអ្វីឡើយ។ ផ្ទះវិឡាតូចរបស់លោកពូស្ថិតនៅក្នុងបរិវេណដីធំល្មម អាចមានសួននិងអាងទឹកតូចមួយសម្រាប់កូនវុធរបស់គាត់។

ចិត្រាចតម៉ូតូហើយចុចកណ្តឹងប្រឹងងើបភ្នែកទៅខាងលើក្រែងមានអ្នកអើតមក ប៉ុន្តែមីងនិស្ស័យហាក់នៅក្បែរទ្វារ។ គាត់បើកទ្វារជាមួយទឹកមុខសស្លេក។

អ្នកមីងរបស់គេជានារីអ្នកច្បាប់ដែលដែលស្រស់ផូរផង់ ទោះបីជាគាត់មានវ័យក្បែរសែហើយក្តី។

«ចិត្រាមករកបងទូ?»

«បាទ! ម្សិលមិញគាត់ខលមក តែខ្ញុំកំពុងរវល់ពេលនេះខលគាត់អត់ចូលទេ!»

ស្ត្រីអ្នកច្បាប់បញ្ចេញភាពមិនស្រណុកលើផ្ទៃមុខ។គាត់ហៅខ្សឹបៗ៖

«ចូលផ្ទះសិនមក!»

ចិត្រាឆ្លើយ«បាទ»ទាំងចិត្តនឹកឆ្ងល់។ គេបណ្ដើរម៉ូតូចូលទៅទុកពីក្រោយកូនសួនដែលស្ងាត់ជ្រងំតែស្រស់បំព្រង។

ពីមុខទ្វារផ្ទះមានបញ្ឈរថូឈើបេងពីខ្ពស់ៗចាំងរលោងរលើប បង្ហាញពីភាពស្ដុកស្ដម្ភនៃកូនផ្ទះតូចច្រឡឹង។

«ប្អូនវុធទៅសាលា?»

មីងនិស្ស័យលើកដៃមើលនាឡិកាពណ៌មាសដែលភ្លឺរន្ទាលលើដៃគាត់ជំនួសឱ្យពាក្យឆ្លើយ។ គាត់ដូចជាកំពុងមានរឿងសំខាន់អ្វីចង់និយាយនឹងក្មួយថ្លៃម្នាក់នេះភ្លាមៗ ប៉ុន្តែអត់ធ្មត់ រង់ចាំឱ្យគេចូលដល់ផ្ទះសិន។

គ្មានអ្នកយាមឬអ្នកថែសួនថែទាំផ្ទះសូម្បីតែម្នាក់ណាបង្ហាញខ្លួន។

សន្ទើមនៅពេលព្រឹកព្រលឹមដក់ក្នុងលំអងផ្កាធ្វើឱ្យស្រទាប់ទងបុប្ផាចោលសម្រស់និងក្លិនក្រអូបពាសពេញបរិវេណផ្ទះ។ គេឈានដល់បន្ទប់ទទួលភ្ញៀវ ដែលតុបតែងដោយរចនាបថលោកខាងលិចផ្សំយពីចូផ្កាឈើបេងនៅឯច្រកទ្វាដែលជារចនាបថចម្លាក់ខ្មែរដ៏ប្រណិត។

«ពូឯងទៅណាមិនប្រាប់ ទៅតាំងពីម៉ោង៤ជិតភ្លឺ! មីងសួរមិននិយាយ គាត់ថានឹងមកវិញ! ទូរសព្ទខលមិនចូលតាំងពីចេញទៅបានបន្តិច!»

«គាត់ទៅម្នាក់ឯង?»

គេសួរទាំងចម្ងល់និងភ័ន្តភាំង។

«មានអ្នកធ្លាប់ធ្វើការជាមួយម្នាក់មកដឹកគាត់ទៅ! ម្នាក់នោះកាលមុនធ្លាប់ធ្វើប៉ូលិសដែរឈ្មោះភណ្ឌ័!»

ស្ថានភាពទាំងអស់ហាក់បីដូចជាជាប់គាំងនៅទីនេះ។ ការស្មាក់ស្មើរទាំងអស់ត្រូវតែកម្ចាត់ចេញហើយគេបញ្ចេញចម្ងល់ទាំងឡាយដែលព្យាយាមលាក់ទុកតាំងពីចូលមក៖

«មីង អ្នកទាំងពីរអត់មានអ្នកបម្រើទេ?»

«មីងនិងពូឯងទម្លាប់ធ្វើអ្វីៗដោយខ្លួនឯង! រាល់មួយអាទិត្យម្ដងមានខាងក្រុមហ៊ុនបោសសំអាតគេមករៀបចំសួន ថែអាងទឹក និងបោសប្រាសផ្ទះ!»

គេអង្គុយចុះលើសាឡុង មីងគេបែរខ្នងទៅឆុងតែ មាត់គាត់នៅតែបញ្ចេញសេចក្ដីបារម្ភ៖

«ពូឯងទម្លាប់ធ្វើអីលាក់លៀមៗមួយរយៈនេះ មីងចេះតែមានអារម្មណ៍មិនល្អ យប់មិញក៏យល់សប្ដិមិនល្អទៀត!»

នៅជុំវិញបន្ទប់នេះមានតែរូបថតពោរពេញទៅដោយភាពសុខដុមរបស់គ្រួសារដែលមានសមាជិកបីនាក់នេះ។ ប៉ុន្តែភ្លាមនោះ គេក្រឡេកឃើញរូបថតមួយសន្លឹកទៀតដែលមានគ្នា៦នាក់។

«ចិត្រា! កូនធម៌របស់ជំនិតកំពុងមានរឿងធំ! ជំនួយការគេព្រឹកមិញត្រូវប៉ូលិសហៅសួរ! អាឡូវគេចេញមកក្រៅបានហើយ តែគេរកវីរៈមិនឃើញទេ! ពូត្រូវតែដោះស្រាយរឿងនេះ! ហើយនៅស្នងការប៉ូលិសមានរបាយការណ៍ច្រើនអាចចោទប្រកាន់គេបាន! ក្មេងនោះជាន់ដានចាស់ប៉ាគេហើយ!

នេះជាសាររបស់ពូគេដែលបានផ្ញើមកឱ្យ។

គេនឹកឃើញដល់Lorenzo មនុស្សនេះនៅមានកំណត់ហេតុថាបាត់ខ្លួននៅឡើយ ឬក៏លោកពូខ្លួនបានរកគេឃើញបានជាប្រញាប់ប្រញាល់ចេញទៅ? គេចុចវាមកអានសាជាថ្មីទាំងបម្រុងលើកសារនេះបង្ហាញមីង ប៉ុន្តែ ពេងតែលើកមកដល់ អ្នកមីងនិយាយឡើងមុន៖

«ម្សិលមិញអ្នកអាមេរិកគេតេមក! លោកជំនិតនិងភីណា កូនប្រុសធំគេបាត់ខ្លួន! ព្រលប់បន្តិចឃើញជំនួយការក្មេងនោះមករកដល់ទីនេះ មិនបានចូលក្នុងផ្ទះទេ ពួកគេនិយាយគ្នាក្នុងសួន! ក្រោយមកពូឯងប្រាប់មីងថា កូនមេធាវីជំនិតឈ្មោះ វីរៈ គេកំពុងមានរឿងធំ ហើយពេលនេះរត់គេចទៅដល់ណាក៏មិនដឹង! មីងសង្ស័យតែអ្នកដែលខលមកឱ្យពូឯងប្រញាប់ចេញគឺគេនោះហើយ! »

ស្ត្រីដ៏ស្រស់សោភាអង្គុយចុះថ្នមៗ។ អ្វីដែលគាត់និយាយបេះបិទនឹងអ្វីដែលក្មួយម្នាក់នេះកំពុងគិត។

គេលើកតែក្រេប។ ភេសជ្ជៈក្ដៅឆ្អួលនេះពិតជាមានក្លិនប្រហើរឈ្ងុយឆ្ងាញ់តែចិត្តគេមានពីភាល់អ្វីមួយពិបាកនឹងអធិប្បាយហើយក៏មិនចង់និយាយចេញមកឱ្យស្ត្រីវ័យក្មេងនេះកាន់តែថប់បារម្ភដែរ។

គេគិតចុះឡើងទម្រាំហាសួរ៖

«អ្នកមីងៗនេះគឺមេធាវីជំនិតនិងអ្នកស្រីភីណា?»

ស្ត្រីមេធាវី ដៀងភ្នែកទៅរកសន្លឹងរូបថតស្រស់ប៉ប្រិមរបស់ពួកគេ។ ក្រសែភ្នែកគាត់ប្រាប់ចម្លើយសម្រាប់ក្មួយម្នាក់នេះយ៉ាងច្បាស់ទៅហើយ។

សម្ដីគាត់តបខ្លី៖

«រូបយូរហើយ!»

គេសួរដោយចង្អុលទៅលើរូប៖

«ចុះក្មេងតូចម្នាក់នេះ!»

ភាពក្រៀមស្រពោនលេចឡើងក្នុងពន្លឺភ្នែកគាត់ធ្វើឱ្យចិត្រាទទួលអារម្មណ៍អ្វីម្យ៉ាងចម្លែក។ បើមេធាវីជំនិតនោះមានតែកូនធម៌ Lorenzo ចុះក្មេងស្រីតូចប្រហែលមួយឆ្នាំដែលឈរនេះ ជាកូនអ្នកណា។

«នីននីនកូនស្រី របស់ពួកគេ! »

ហេតុអីពេលអ្នកមីងនិស្ស័យនិយាយអំពីកុមារីនេះគាត់ហាក់ស្រពោនទៅៗ?

ចិត្រាថ្លើមធំប៉ុនណាក៏មិនទាន់ហ៊ានហារមាត់សួរ នូវអ្វីដែលចាស់ទុំមិនទាន់និយាយប្រាប់នោះដែរ។នេះជាទម្លាប់របស់គ្រួសារគេ។

គេនៅស្ងៀមស្ងាត់ក្រេបតែបណ្ដើរ ចិត្តទន្ទឹងរង់ចាំបណ្ដើរ ក្រែងលោឮស្ត្រីម្នាក់នេះនិយាយអ្វីបន្ថែម តែមិនអ៊ីចឹង គាត់បែរជាហៅនាយឱ្យក្រោក៖

«មកណេះចិត្រា មីងមានរបស់ឱ្យក្មួយមើល!»

គេក្រោកតាមគាត់ហើយឆ្ពោះទៅបន្ទប់មួយនៅឯខាងស្ដាំដៃ។ វាទំនងជាបន្ទប់Office។

មីងនិស្ស័យរុញទ្វារចូលទៅ វាបែរជាគ្មានតុកៅអីអ្វីសម្រាប់អង្គុយធ្វើការទេ ប៉ុន្តែមានសាឡុងធំវែងមួយត្រូវគេរុញចោលទៅម្ខាងហើយផ្ទាំងក្រដាសស យ៉ាងទូលាយត្រូវបានបិទពេញមួយជញ្ជាំង បាំងទាំងមាត់បង្អួចនៃផ្ទះនេះ។

ស្ត្រីអ្នកច្បាប់ ចុចកុងតាក់បើកភ្លើង។

នៅលើផ្ទាំងក្រដាសដ៏ធំនោះមានស្នាមគំនូសជាច្រើនប្រើហ្វឺត មិនថាពណ៌ខ្មៅក្រហមបៃតងខៀវគឺមានទាំងអស់។

ចិត្រា នឹកឃើញមួយរំពេចដល់ស្នងការRoyពេលសម្លឹងឃើញអក្សរ សមោសរពណ៌ព្រះចន្ទ និង ឈ្មោះ Lorenzo មហាវីន Roseព្រមទាំងអ្នកឯទៀតដែលមានពាក់ព័ន្ធនឹងការបាត់ខ្លួនរបស់ពួកនារីអភិជន។

«ពួកប៉ូលិសជំនាញគេចូលចិត្តគូរវាសដើម្បីអង្កេត? ចរិតពូខ្ញុំនិងស្នងការRoyមានចំណុចដូចគ្នាដែរតើ? ប៉ុន្តែឱត សាម៉ុនក៏ជាប៉ូលិសជំនាញ យើងនៅផ្ទះគាត់យូរហើយម៉េចមិនដែលឃើញគូសវាសរបៀបនេះ?»

«មួយល្ងាចមិញ គាត់សំងំក្នុងនេះ ហើយគូសរបស់អស់នេះ! មីងមិនដឹងថាគាត់ចប់ពេលណាទេ មីងចាំគាត់យប់ជ្រៅពេកក៏ចូលសម្រាក រហូតទាល់តែទូរសព្ទដាស់គាត់ឱ្យក្រោកឡើងទើបមីងដឹងខ្លួន!»

មិនថាមានបញ្ហាអ្វីកើតឡើងក្នុងពេលនេះ គំនូសដូចផែនទីនៅលើផ្ទាំងក្រដាសហាក់បញ្ជាក់

ប្រាប់គេជាស្រេចថា ពូខ្លួនបានចំណាយពេលពេញមួយយប់ក្នុងការគិតរកមធ្យោបាយបំបែកក្តីនេះ។

«គាត់ប្រហែលជារកឃើញពន្លឺអ្វីមួយហើយតក់ក្រហល់ចេញទៅតាមរកវា?»

គេរអ៊ូម្នាក់ឯងស្រាប់តែមីងថ្លៃនិយាយអង្វរៈ

«ចិត្រា! ក្មួយនៅខាងណោះស្រាប់! ប៉ូលិសប្រហែលគេមានលទ្ធភាពរកឃើញថា ពូឯងទទួល

ខលអ្នកណាហើយនិយាយរឿងអី?»

ស្ថានភាពមិនទាន់ដល់ដំណាក់កាលត្រូវស្លន់ដូច្នេះឯណាហ្អី? គេគិតម្នាក់ឯងទាំងងាកមក សម្លឹងគាត់។ ស្ត្រីម្នាក់នេះមានទុក្ខព្រួយជាច្រើនលាក់ទុកក្នុងកែវភ្នែកល្ហល្ហេវ។ តើស្អីទៅធ្វើឱ្យគាត់អន្ទះសាសូម្បីតែឆែកទូរសព្ទប្តីក៏ចង់ធ្វើ?

«អ្នកមីង! ពូជិតមកវិញហើយដឹង?»

គេហាក់ចង់បន្ទោសគាត់ស្ងាត់ៗថា ប្តីទើបតែបាត់ប៉ុណ្ណឹងម៉ោងម៉េចក៏ចាំបាច់ភ័យស្លន់។

គាត់ស្លេកហើយក្រពាត់ដៃថយទៅក្បែរជញ្ជាំងឈើរស្ងៀមទីនោះ។

គេនិយាយបន្ថែមទាំងសម្លឹងគាត់៖

«អ្នកមីងតាមពិតមានអីចង់និយាយប្រាប់ខ្ញុំទៀត?»

គាត់ឈ្ងោកមុខ ឯគេផ្តោតសម្លឹងគាត់ដោយក្តៅឆេវឆួល់។ មុនពេលសម្រេចចិត្តនិយាយខ្លះលាក់ខ្លះ៖

«ពូឯងធ្លាប់មានរឿងជាមួយគេខ្លះ មួយរយៈចុងក្រោយនេះ!»

ពេលវេលាច្រើនទេ តែការសំខាន់ត្រូវធ្វើមានច្រើនអនេក គេដឹងខ្លួនឯងថាត្រូវតែចាកចេញពីទីនេះប៉ុន្តែមុននឹងទៅ គេត្រូវតែដឹងការពិតដែលមីងគេកំពុងលាក់។

«អ្នកមីងត្រូវតែនិយាយឱ្យខ្ញុំដឹង!»

ចិត្រាអូសដៃគាត់មកអង្គុយលើសាឡុង។ ស្ត្រីអ្នកច្បាប់មិនសមថាមានលក្ខណៈមិននឹងនដល់ថ្នាក់នេះសោះ។

គាត់ហាក់ត្រជាក់ចុងដៃ បានជាគេនិយាយលួងភ្លាម៖

«អ្នកមីង! ពូជាមនុស្សឆ្លាតវៃ មីងដឹងស្រាប់ហើយ! គ្មានអ្នកណាធ្វើអីគាត់បានទេ!»

«គាត់ខានយូរហើយ! កាំបិតមិនសំលៀងយូរ វាអាចច្រេះ! ចិត្រា ប្រហែលជាបីបួនខែមុន! មានប៉ូលិសផ្កាយធំៗមករកគាត់!»

គេជ្រួញចិញ្ចើមទៅតាមការភ្ញាក់ផ្អើលដែលស្ត្រីនេះកំពុងនឹងបានផ្តល់មកឱ្យ។

«ក្រែងពូខ្ញុំឈប់ពីប៉ូលិសហើយ?»

គេប្រុងថាពោលសួរពាក្យនេះ ប៉ុន្តែក៏ទប់ចិត្តវិញរង់ចាំស្តាប់។